N°3 "Sovannahong" R. le 6-1-54.

# សុវណ្ណហង្សទី៣



INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

ទ៊ូ-ទ៊ូ
118

# បញ្ជីសៀវភៅរបស់បណ្ណាគារ

## ជីជំ-ផួង-ហ៊ួត

លេខ ៣០ ស្ទួនវិថី ប៉ាស្ទ័រ ក្រុងភ្នំពេញគឺ:

| | | | |
|---|---|---|---|
| ១- | ពុទ្ធប្រវត្តិពាក្យកាព្យ | ថ្លៃ | ១៧៛០០ |
| ២- | ភេសជ្ជខន្ធក ទី ៦ | ថ្លៃ | ២០៛០០ |
| ៣- | ប្រស្នាពុទ្ធសាសនា | ថ្លៃ | ៨៛០០ |
| ៤- | សុន្ទរកថា | ថ្លៃ | ៧៛០០ |
| ៥- | ឃរាវាសធម៌ ទី៥ ច្បាប់ទូន្មានកូនចៅ | ថ្លៃ | ៥៛០០ |
| ៦- | សំវេគកថា | ថ្លៃ | ៤៛៥០ |
| ៧- | ប្រជុំពុទ្ធភាសិត | ថ្លៃ | ៨៛០០ |
| ៨- | បញ្ហាសង្គម | ថ្លៃ | ១៤៛០០ |
| ៩- | បុគ្គលកថា | ថ្លៃ | ៥៛០០ |
| ១០- | ហិបហោះ | ថ្លៃ | ៨៛០០ |
| ១១- | សន្និសីទ ស្ដីពីសាសនា, បទបញ្ញត្តិ គោលធម៌របស់-សាសនា និងការឧបត្ថម្ភព្រះពុទ្ធសាសនា | ថ្លៃ | ៥៛០០ |
| ១២- | ប្រស្នាវិនយបញ្ញត្តិ ទី ១ | ថ្លៃ | ៧៛០០ |
| ១៣- | ,, ទី ២ | ថ្លៃ | ១២៛០០ |
| ១៤- | ប្រជុំសិក្ខាបទ | ថ្លៃ | ១០៛០០ |
| ១៥- | សន្ទនាត្រៃភាសាខ្មែរ-បារាំង-យួន | ថ្លៃ | ១៥៛០០ |
| ១៦- | សរសេរតាមសូត្រ-ពន្យល់ | ថ្លៃ | ២០៛០០ |
| ១៧- | រឿងម៉ាកប៉ាយុងកែវ ទី ១-២-៣ | ថ្លៃ | ៩៛០០ |

1953 - 3
ប. 2



REGIE DU DEPOT LEGAL
ARCHIVES NATIONALES
COTE B-114-1365 82

## បទពំនោល

ក្សិណវិរុឡមេឃឫទ្ធី មើលយល់ពាដី ពុំត្រូវសណ្ដាំឡើយណា ៗ
យក្សាក្រេវក្រោធមហិមា លើកពេជ្រផង់ផារ ប៉ង់នឹងពិឃាតមនោម័យ ៗ
អស្សតរបេរជាញជ័យ ពុំផាស់ក្សត្រថ្ងៃ បង់លង់ឫទ្ធីបេស្តា ៗ សូវ
ស្លាប់ទៅតាប់គួរជា គិតស្រេចអស្សពាហ៍ បរបាថាវ៉ុយយក្សយង់ ៗ
ឈោកគ្មីងឹមង៉ាមផ្ទេងផ្ទង់ ល្អបមើលពោះត្រង់ ព្រះឥន្ទព្រះអគ្គិស្ដេចជុំ ៗ
ទាំងពីរសាន្តសុខមនោរម្យ បើតើនឡើងសម ម៉ង់ក្ស័យជីវិតមរណា ៗ
បូរមឹងថយបេញស្ពក៉ រកអ្វីយក្សា កំផ្ទុបកំផ្ទើមមុខមាត់ ៗ វិរុឡអសុរ
ក្រោធក្ដាត់ ព្រោះវ៉ាសេះសត្វ មកហ៊ានពាយង៉ាយអញក្រៃ ៗ អញ
ជាស្ដេចស្ដេងដៀស្ឋជ័យ ឥតអ្នកដងទៃ ប្រកួតប្រកាប់ពុំបាន ៗ ម្ដេច
មឹងភង់រង់ហៅហ៊ាន ដៀលត្មុះពុំមាន កោតខ្លាចឫទ្ធីបេស្តា ៗ ម្ចាស់
មឹងមកពីឯណា ហៅហ៊ានមហិមា ចូលដេកក្នុងសាលាអញ ៗ វិរុឡ
អសុរសុះសេញ ខាំមាត់ស្វាញសេញ ក្រទាក្រតើនចូលចាប់ ៗ
អស្សតរបេរវៃឆាប់ ធាក់យក្សស្ទើរស្លាប់ ពុំឲ្យដល់ព្រះភ្លូបាល ៗ យក្ស
ក្រោធលោលោតប្រហារ លើកពេជ្រព្រាសព្រាល បំណងសំពង់
អស្សពាហ៍ ៗ បង់ឲ្យក្សិណក្ស័យមរណា អស្សតររ៉ា ខាំធាក់
អសុរបក្រៃ ៗ ប្រឹនដង់ប្រឹនក្រោពកក្រៃ យក្សាស្ទើរក្ស័យ ដួល
ដេកលើផែនពសុធា ៗ សេះធាក់វិរុឡយក្សា ដួលហើយស្រែកថា ពះ
វាអសុរបក្រៃ ៗ ម្ចាស់អញស្ដេចជុំអាស្រ័យ ម្ដេចមឹងគាបក្រៃ

ប្រមាទពិឃាតក្សត្រា ៗ មឹងឯងដួលដេកពសុធា ស្តេចមឹងលីលា ក្រោក
មកប្រយុទ្ធទៀតនៃ ៗ អញខាំក្បាលមឹងឲ្យក្ស័យ ឥឡូវធាប់ក្រៃ
សមបីមឹងមកពុំលែង ៗ វិរុឡមេឃដេកប្រខែង ហត់ហបស្អុះស្អែង
កន្ទេះកន្ទះដួលចុះ ៗ បែកឈាមហាមស្ពូស្អុស ស្មើរក្ស័យកាល
នោះ យកក្បាលឈប់សែពស្ត្រមន្ត ៗ តេជះគាថាធុតលន់ យក្សមាន
ជីពជន្ម ស្អាញស្អុះក្រាញក្រោកឡើងថ្វាត់ ៗ ស្ទាកស្ទាមបេញឈាម
សោតបាត់ ជិតជុំដាថ្វាត់ គ្រវាត់គ្រវែងឯងផា ៗ ស្រែកស័ព្ទសន្ធាប់ទៅថា
វុយសេះពាលា អាផាស់ម្ចាស់អាឡើងខ្ញុំ ៗ តតាំងបំបាំងដាញជ័យ
ជួយអាចក្រៃ ឥឡូវកុំឲ្យផ្សូរផ្សង ៗ យកក្បាពាលាទ្រើសឃ្នង លោចាប់
តម្រង់ តម្រូវកែបសេះអស្សពាហ៍ ៗ ស្អុះស្អាត់ផាយផុតហើយណា
ក្រុងយក្សពាលា បែរបេរត់ស្អុះមហិមា ៗ យកក្បាពាលាវ៉ាងវៃ លោ
ចាប់កែបនៃ មនោម័យផាផាយពុំទាន់ ៗ វិរុឡចាប់កែបខ្ញុំខាន់ លោត
ឡើងជិះផាន់ កន្ត្រាក់បង្ហៀរផ្សៀរផ្ទោះ ៗ រត់បេញពីក្សត្រកាលនោះ
មនោម័យហៀរហោះ ជម្រូវជម្រង់នគរ ៗ ព្រះបាទកំពលយក្ស
សេះស្រែកហៅថា បពិត្រកំពលបុទ្ធិក្រៃ ៗ ដៀតវិរុឡលួចខ្ញុំនៃ ហោះ
ហួសហៀរវ៉ៃ ចោលក្សត្រកណ្តាលអត្វា ៗ កំពលអសុរយក្ស
ស្តាប់ពាក្យអស្សពាហ៍ ម្ទីមាចាប់ម្ទូរសារជ័យ ៗ ទទូងកើរធាប់ក្រៃ អស់
អគ្គមន្ត្រី បរពលអសុរយក្ស ៗ ហៀរហោះផ្លុកផ្លោះវេហាស៍ តាម
ទាន់អស្សុក វិរុឡមេឃនភាល័យ ៗ ព្រះបាទកំពលនរបតី ស្កាត់

មុខអសុរី ថាវុឺយអសុរទ្រើសឃ្មង ។ មឹងឯងចិត្តធំកន្ទង ចាប់សេះ

ហោះផ្សង ចោលអគ្គិព្រះបាទក្សត្រា ។ មនោម័យនេះនៃជាតិជា ទី

នាំងក្សត្រា ម្ដេចមឹងហ៊ានលួចជិះលេង ។ មឹងក្ស័យឥឡូវនេះឯង ចិត្ត

ចោរកំហែង កំហល់កំហុសពុំគាប់ ។ វិរុឡមេឃមានស្ដែងស្ដាប់

សន្ធឹកសន្ធាប់ ឆ្លាស់ឆ្លើយថាវុឺយពលមារ ។ លំពែងកែវពេជ្រពីឃ្លាំង

យកប្រថយកម្លាំង សន្ទុប់ចំប្រប់អគ្គា ។ វិរុឡអសុរយកព្រា ក្សីណ

ក្ស័យមរណា នឹងផែកលំពែងសិលប្រជ័យ ។ កំពលមានបុទ្ធីក្រៃ វិរុឡ

ក្សីណក្ស័យ ស្រេចទើបកំពលយកព្រា ។ សួរសេះមនោម័យទៅថា

អ្នកហោះវេហាស៍ ម្ដេចឡើយឲ្យយក្សាមាន្យ ។ ចាប់ជិះចោល

ក្សត្រប្រធាន នឹងនាងកល្យាណ ស្ដេចខាននៅទីឋានណា ។ មនោម័យ

ស្ដាប់ហើយឆ្លើយថា កាលក្សត្រទ្រហា ចេញចាកនគរពជរម្យ ។

ហិបហោះផ្ទុកផ្ទោះដោយដំ- ណើរនៃអញខ្ញុំ លឿនលន់ពេកពន់

មហិមា ។ ទើបក្សត្រិកដកញ្ញា ញាប់ញ័រអគ្គា សន្ទុប់ចំប្រប់ស្មើរ

ក្ស័យ ។ ស្ដេចទតយល់សាលានៃ យក្សាចង្រៃ ទាញទុងជម្រង់

មីម្មា ។ ខ្ញុំបានក្រាបទូលឃាត់ថា សាលានេះណា បេល់ជាអសុរ

យក្សនៅ ។ ស្ដេចពុំស្ដាប់ពាក្យខ្ញុំកូវ កើប ហោះចុះទៅ ផ្ទុកង សាលា

យក្សយង់ ។ អសុរវិរុឡពំលុង រាមកជម្រង់ ប្រយុទ្ធប្រយោជន៍

ចេស្ដា ។ ខ្ញុំយុទ្ធគាំងនឹងរ៉ា កាលព្រះពជា យកព្រាចាប់កែបជិះហោង ។

ចោលក្សត្រព្រំងតីរនៅនោះ ពិតពុំដឹងស្មោះ ជាស្ដេចទៅឋានឯណា ។

កំពលស្លាប់ហើយបរា ញ័រអស់អង្គា គិតដល់ព្រះអង្គពីរក្សត្រ ។
ត្រាស់ថាហៃសិទ្ធពរត្ន ព្រោះយើងតាមក្សត្រ ឲ្យដឹងដំណើរដើមក្តី ។
តែរកបញ្ឈប់បានបី ថ្ងៃសឹមវិលវៃ ទៅតាមព្រះបាទទពជា ។ កំពល
អសុរយក្ស គិតព្រមនាំគ្នា លីលាបរបួលប៉ុរី ។ សេនាយោធាមន្ត្រី
ហៃក្សត្រអសុរី បរបួលដល់ឋានភជរមៀ ។ លំហើយកាយាមើលចំ
ផៀងសាប់ឈាមក្រំ លុះបានបំថ្ងៃស្តេចជា ។

## បទកាកគតិ

ទឹងថ្ងៃស្រងី ពីព្រះចក្រិ ផ្ទុំនៅសាលា កាលក្រោយអសុរ
វិរុលមេឃា ចាប់ពផអស្សពាហ៍ ហោះហួសចាកឋាន ។ លុះព្រឹក
ស្រេចស្រាង សុរិយាបំព្រាង ទិសទីបូពិបាន ស្តេចតើនឡើងស្រេច
សម្តេចក្សត្រក្សត្ត ផាស់នាងកល្យាណ តើនចាកបន្ទំ ។ រកពផ
អស្សពាហ៍ ពុំយល់ក្សត្រា គន់គិតបារម្ភ ប្អូនអើយសេះបាត់ សូន្យ
ស្ងាត់ផែនដី ក្រែងយល់យើងផ្ទុំ ដើររកគោក្តា ។ ចូរប្អូនចាំពេង
បង្ងឹងបរផ្គង រកពផអស្សពាហ៍ ក្រែងទៅរកស៊ី ដោយទីគង្គា នាង
នាថធីតា ប្រចាំនៅទិត្យ ។ ព្រះពោធិសត្វ បរពេញត្រាប់កាត់
សត្វទីឋានគ្រៅ រកពុំយល់នៃ ក្សត្រថ្ងៃចមទៅ បរបួលថ្កានពៅ
បតចាំសាលា ។ ដល់ហើយព្រះអង្គ ព្រះសុវណ្ណហង្ស ទុនទុបជា
យា ប្អូនអើយកម្មព្រេង យើងឯងកាលគ្រា ឯងឲ្យឃ្លាតឃ្លា អស្សតរ
មនោម័យ ។ ប្អូនអើយស្រុកបង នៅឆ្ងាយកន្ទង់ កន្ទុំផ្លូវព្រៃ ញាត

ស្បាតបន្ទា មាគ៌ាលូនលៃ លូតលាស់ត្រៃឈើ ត្រឈឹងសាខា ។
សត្វព្រៃនរដាស សុទ្ធសឹង្ហមាស រមាំងខ្លាំងខ្លា ដំរីធំៗ សឹង្ហ
ចាំមាគ៌ា ក្លឹកក្លាំងកាយា ភ័យភិតខ្លាចមរ ។ ស្ដេចថ្ងូញពេកក្ដាត់
ឱបអង្គប្អូនរត្ន ថ្ងូញទៅអស្សតរ ឱ!ពជមនោម័យ ម្ដេចនៃបញ្ចរ
បោលប្អូនឲ្យមរ និត្យនៅក្នុងព្រៃ ។ ឱ!កម្មពៀរព្រេង អាចមក
បង្វែង ព្រាត់ប្រាសទីទៃ ឱ!សមអស្សតរ បវរមនោម័យ ក្សិណា
ក្ស័យជីវី ជីវិតមរណា ។ ឱ!កេតសុរិយន្ត ធ្លាប់វង់នៅក្នុង ប្រា
សាទរចនា ឥឡូវលំបាក តោកយ៉ាកយាត្រា ស្នូរស្បាតបន្ទា មុត
មាសជាំក្រំ ។ ពុរពងបាទា នឹងយាងយាត្រា ទៀយណាស់ខិតខំ
ឱ!បាបពៀរកម្ម នាយនាំឲ្យអំ- ពល់ពេកពិតពុំ ដឹងដើមប្តេះណា ។
ឱ!ដូចអ្នកយក លំពែងចាក់ដក ក្ដៅផល់ឱរ៉ា ឱរះយកថ្មើម ដង្ហើម
ទ័យា សាប់ស្ងួតនេត្រា នេះនឹងក្សិណក្ស័យ ។ សង្រួមតែសេះ
ជាតិជាជំទិះ ជំនាន់ធាប់វៃ ឥឡូវមាររបេះ ប្រឡេះពីដៃ រូបរង់ទុក្ខ
ភ័យ ណាស់នឹងមរណា ។ ស្ដេចសោយសោកសព្វ ប្រះប្រាណ
សន្ធប់ ស្មើរក្ស័យជន្ម ទើបវរក្សត្រ ប្រឹមប្រីយសោកា នាងយក
គន្ធា លុបលាបព្រះភ័ក្ត្រ ។ គ្រាហ៍ព្រះមហាក្សត្រ ពន្ធកបរមត្ថ
ស្ដេចបានក្បាក្បាក់ មានព្រះស្មារតី ក្សត្រីវរលក្ខណ៍ ទូលក្សត្របម
បក្រ ឥស្សូរសិរសា ។ បពិត្រព្រះអង្គ ប្រសើរទ្រើសទ្រង់ កុំស្ដេច
សោកា ហេតុកម្មយើងឯង ពីព្រេងឲ្យឃ្លា ឲ្យឃ្លាតអស្សពាហ៍ ចាក

បេញចំបែង ។ សូមស្តេចកំសាន្ត ព្រះព្រៃគ្រៀមក្សាន្ត ឲ្យស្រាលខែង
វ៉ែង ទុក្ខខ្ញុំផងក្រៃ នាថ្ងៃនេះឯង យើងត្រាច់ចរស្វែង លះលាកសាលា ។
ទៅទិសនាយ ទោះជិតទោះឆ្ងាយ ប៉ុន្មានក្តីណា យើងទៅឲ្យដល់
មណ្ឌលនគរ ពួរគ្ននាយណា កុំផ្សើលង់ឡើយ ។ ព្រះពោធិសត្វ
ស្តាប់ព្រះប្អូនរត្ន បន្ទូលទោះហើយ បន្ទោសោកា ក្សត្រាត្រាណត្រើយ
ពិតពុំលង់ឡើយ ពព្រះប្អូនស្រី ។ ចុះពីសាលា យាងយាស់យាត្រា
ដោយដងព្រឹក្សព្រៃ ស្រណោះអស្សពាហ៍ យាត្រាដោយព្រៃ នឿយ
ណាស់ចក្រី ដាក់ស្រីសុរិយន្ត ។ ចុះពីបង្កេះ មហាក្សត្រទាំងទ្វេ
សោយសោកលឿនលង់ យាសយាងព្រះបាទ ទ្វីឃាតជម្រង់ ជម្រូវ
ភ្លោះត្រង់ ទិសទីបុរី ។ នាងនាថជាយា យាងយាសយាត្រា តាម
ព្រះចក្រី ព្រះបាទពូជពង្ស វង្សវង់ទុក្ខក្រៃ នឿយណាស់ល្ហិតល្ហៃ
ខ្លួញទុលទុក្ខា ។ តត្រុកស្បូវសព្រាត ញញ័រញញាត ឃ្វាយឃ្វៃ
បន្ទា សសិតស្បូវសព្រាំង ស្បូវក្ញាំងត្រៀបត្រា មុតដាប់បាទា ឈាម
ហូរហាម ។ ព្រះពោធិសត្វ យល់នាងស្រីរត្ន យាងយាសដើរ
តាម លើកឡើងពទៀត ទៀងទតសំណាម មុតដាប់ហូរឈាម ពុរ
ពង់បាទា ។ ស្តេចជាទុក្ខ ពីព្រៃធំនាយនាំ បាត់អស្សពាហ៍ ឲ្យ
ប្អូនដើរជី ដើងស្រីពុំឆា ពុរពង់រអា រអាមជាំក្រំ ។ ហូរឈាម
សស្រាក់ សស្រោបឥតអាក់ ឥតឥម៉េះសម ឈើទៀបខ្លាចផ្សា ជា
យាទុត្តម សម្តេចបរម វែសនសោយសោកា ។ ខំបរូតរះ ពះ

តើបប្រទះ សត្វផងនានា ដំរីខ្លាធំខ្លាំង ខ្ទឹងខ្លាំងអង្គលា កន្ធរីកន្ធក

សឹង្ហសាំងតាមរី ៗ ខ្លាធំដំបង សាហាវយង់ឃ្នង ត្រាច់កាត់រកធី

តាប់ប្រើសផ្លូកត្រាយ ទន្សាយឈ្លាលញី ពាំនាំទៅធី ទៅទូលព្រៃ

ៗ នាងយល់សព្វសត្វ កិតក័យស្ទើរបាត់ ស្មារតីទ្រញុំ ស្ដេចព

ជាយា ក្សត្រាខះខំ អស់សត្វផងពុំ បៀតបៀនក្សត្រា ៗ ព្រះ

ពោធិសត្វ ទៀយណាស់ពេកក្តាត់ ពុរពងបាទា នឹងគ្រួសខ្សាប់ក្តៅ

ឈាមស្តៅមហិមា ដាក់នាងជាយា ដើរដោយដីស្មោះ ៗ នាងដើរ

លំបាក លំបិនគោកយាក ទ្រែមទ្រមបំពោះ ដំពប់បាទា ជាយា

ដួលបុះ ក្សត្រាបួលស្មោះ ថ្នាក់ថ្នមមហេសី ៗ ពត្រាច់យាត្រា

វែងវំមហិមា ដល់ផ្នូរទទី គន្ធមាទន៍ធំសល់ គីសើរណាំងស្រិ

យក្សាត្តិយ មោហាសាមាន្យ ៗ ហេតុពៀរសុរិយង្គ នឹងព្រះ

ពោធិ៍ពន្ស ឯងឲ្យឃ្លាតឃ្លាន ភ្លេចក្លាំងនិមិត្ត ឥតឫទ្ធិខាន់ខាន ក្សត្រ

ថ្ងៃប្រឋាន នាំនាងទៅ ៗ យាត្រាដោយជង ផ្លូវទឹកទំនង់ ទំនៀមនទី

ឈប់ឈមព្រះក- ក្រាអ្នកតាំងទ្វី គយគន់នទី រកទូកឆ្លាស់ឆ្លង ៗ

## បទពំនោល

កាលនោះកីសើរទ្រើសឃ្នង ឋិតឋានដោយជង ផ្ទៃលង់ទន្លេនោះ

ណា ៗ. មានបុប្ផស្រីមួយនាំរា បិសាចគង្គា ឋិតនៅគន្ធមាទន៍នទី ៗ

តាំងព្រះឥស្សរសិរសី ឲ្យនៅដលស័យ អាយុបាន៤ម៉ឺនឆ្នាំ ៗ ជាហេតុ

កិនកេទផលកម្ម ជីវិតក្ស័នឆ្នាំ នោះនឹងកីសើរអស្សុរា ៗ នឹងនៅពុំបាន

ឡើយណា ចង់លេងផលសា សប្បាយរំហើយរមនា ។ ស្រេចដើរមក
យល់ពផា នូវនាងធីតា ប្របផ្នូរទន្ទូរនោះនៃ ។ គីសើរនាំយក្ស
ចង្រៃ ជាអញនៅនៃ ហាននេះ៧ម៉ឺនឆ្នាំ ។ ពុំដែលយល់អង្គមនុស្ស
ម្នា មុះមកពីណា ដំពាក់ដំពើបក្អែកស្មោះ ។ ទើបឃើញឥឡូវនេះ
ម្នោះ គួរអញផ្ទុកផ្ទោះ ចាប់ស៊ីចំអែតអង្គា ។ គិតស្រេចលបលួច
ពេក យល់រូបក្រោ ល្អល្អះត្រកាលប្រុសផង ។ តោះទេព្តានៅ
ស្អួតហាង ពុំមានរំលង រំលងបង់នេះឡើយណា ។ សមត្តប្រពន្ធ
ទឹងគ្នា សឹងល្អសោភា អស់អញរកលល់ម្តេចនៃ ។ ទឹងបានរក្នេះ
ជាប្តី ត្រូវក្រដីរ៍ ជីវិតមូលមួយផងគ្នា ។ អ្នកនេះរូមរិះលេលា ប្របផ្ទេរគង្គា
ប្រាប្នាទឹងធ្ងូងផលធី ។ គួរអញបរបេញទៅនៃ និមិត្តឆាប់ខ្ញី ជាទូកអ៊ុំមក
ផល់ថ្វាត់ ។ គិតស្រេចគីសើរបរកាត់ និមិត្តឆាប់ក្តាត់ ជាទូកប្រាំផាក់
នៅ ។ ខ្លួនកើតជាចាស់ឃោរឃៅ ឆ្មេញបាក់សក់ស្កូវ កំព្រឹ កំព្រេន
អបលក្ខណ៍ ។ អ៊ុំទូកទៀបចាល់ព្រះកន្ត្រ ក្រោវលក្ខណ៍ បរិណ្តត
បណ្តាយផលសា ។ ធ្វើជាហត់ហបឆាកស្មា បានបុកម្នា រទាក
រទាកបកពម ។ ខ្នងកោងប្រគ្រោងវ្រៃមទ្រម ទ្រេតទ្រោតប្រណាម្យ
ទពាក់ទពាមបាតា ។ ព្រះសុវណ្ណហង្សថ្ងៃថ្វា យល់ចាស់ផក អ៊ុំទូកមក
ដោយផលសៃ ។ ពុំដឹងជាយក្សចង្រៃ ក្រឡាឡើយនៃ ស្មានជា
មនុស្សអ៊ុំធ្ទះធ្ងន់ ។ បន្ទូលសាសង់ទៅគ្គង ខ្ញុំសូមទៅផង បម្លងបាន
ផល់ត្រាណត្រើយ ។ បុណ្យអ្នកយាយតន់ប្រមាណ គង់យាយប្តើងបាន

ដិតកល់ផាត់លើសិរសា ។ ដូនចាស់ក្រឡាស្រដី មាយាពេកក្រៃ ថា
ម្ចាស់ឯនាយបុស្បា ។ យូរយាពុំបានទេណា ដេរក៏យផ្កាសា ថាប្រើ
ទៅណាពុំឆាប់ ។ ព្រះសុវណ្ណហង្សស្តេចស្តាប់ លើកករប្រញាប់
សំពះដូនចាស់បុស្បា ។ តាំងនាងសុរិយវង្សផងណា លើកករវន្ទា អ្នក
យាយអើយយាយអាសូរ ។ ចម្ងន់យើងផងកុំយូរ យើងសុំឲ្យបួល អ្នក
យាយអន្គុយសៀមហោង ។ ក្សិណាយាយធ្វើបុណ្យបានធ្ងន់ សត្វដល់
ត្រើយផង បានបុណ្យអនន្តគណនា ។ កំសើរស្តាប់ហើយធ្វើជា ទឹង
ទាក់នាក់ ប្រក់ក់តផងថាហៃ ។ មាសយាយបើធ្ងន់ឆាប់ៃ បរបុះទាន់
ថ្ងៃ យាយទឹងអាលបរលើណា ។ ម៉្ញូះសមទន្ទឹងមហិមា ប្រទេចផ្កាសា
មាសអើយបរបុះមកឆាប់ ។ ព្រះពោធិសត្វស្តេចស្តាប់ នាំនាងប្រញាប់
បរបុះដល់ទូកនាក់ ។ ពុំដឹងជាយក្សក្រឡា ស្តេចឲ្យធីតា បរបុះកន្សៀ
ដប្រឹង ។ ស្តេចចុះឯកក្បាលពុំលង់ ឲ្យដូនចាស់អង- គុយនៅកណ្តាល
នាក់ ។ ខិបខាញបរបេញមុំមា កំសើរអសុរ គន់គិតសម្លាប់ក្សត្រិ ។
ទឹកដល់បិសាចប្អូនស្រី បូរនាងទៀងទី លីណាមកជួយបងហ៎ ។ បិសាច
នាំយក្សអសុរ ដឹងដើមហេតុណា ក្រឡាជាព្រះខ្ញាំងក្រៃ ។ លោក
លៀមផលសៃ ឲ្យោកបក់ខ្ញាំងក្រៃ សន្ទឹកសន្ទាប់សព្វសល់ ។ កី
សើរមិលយង់យល់ ក្សត្រក្សត្រីទិមិល រលំខំអុំនាក់ ។ យល់ក្សត្រ
ទេតនេត្រា ក្សិណាយក្សអសុរ ចានរវជាយាទិមិល ។ ធ្លាក់កណ្តាល
ទឹកធំសល់ ហើយទើបអសុរ ប្រែប្រាណក្រឡាខ្ទួនហោង ។ ដូច

នាងស្រស់ស្រីទង់វង់ ធុនអុំទូកដង្ក លឿនលន់ពេកពន់មហិមា ។ ព្រះសុវណ្ណហង្សក្សត្រា ទំអុំនាវ ពុំបានមើលមកកន្សៀ ។ លុះបានដល់ត្រើយហើយនៃ ព្រះបាទជៀស្តជ័យ ទតយល់ក៏សើរយក្សា ថាជានាងនាថធីតា ពុំដឹងមាយា យក្សាប្រែប្រាណឡើយនៃ ។ បន្ទូលត្រាស់ថាមាសថ្លៃ ជូនបាសនោះនៃ គាត់ទៅឯណាពុំយល់ ។ ក៏សើរយក្សាកំហល់ ទូលព្រះទសពល ថាយាយម្ចាស់ទូកនោះណា ។ កាលខ្យល់ព្យុះទល់នាវ ធ្លាក់ក្នុងគង្គា ប្រាំបាប់យកពុំបាន ។ ខ្ញុំថាជាក្សត្រសោកណា ប្រាប់ហើយខ្ញុំខាន ទំអុំឲ្យដល់ត្រើយត្រាណា ។ ស្ដេចស្ដាប់នាងយក្សសាមាន្យ ប្រាប់ហើយក្សត្រក្សាន្ត អាសូរជូនបាសផង ។ គាត់មានគុណធ្ងន់មហិមា គាត់ឲ្យនាវ ធ្លាស់ធ្ងន់មកដល់ត្រើយស្នោះ ។ ប៉ុន្តែនាងឡើងពីទូកនោះ បងនាំនាងនោះ សំដៅលំនៅត្រាមា ។ ទូកជូនបាសហោលនៅនា ទទឹកផលសា យើងដើរនោះទៅនគរ ។

## បទកាកគតិ

ព្រះពោធិសត្វ ពន្ធកពុទ្ធរតន៍ នាំនាងចេញចរ ស្ថានកេតសុរិយគ្គ បញ្ចគ្គបវរ រូបកាំស្នោះសរ ឥតឲ្យសង្កា ។ នោះគាំងក្រិត្យក្រម មារយាទពិតពុំ ឃ្មៀងឃ្មាតលក្ខណា កើតខ្មាសក្ដុងគ្គ ពូជពង្សជាយា និម្មិតយក្សា ពិតពុំឃ្មាឃ្មាត ។ ស្ដេចចរលេលា ដោយដនព្រៃក្បា ឆ្ងាយពន់សល់ខ្នាត កេតសុរិយគ្គយក្ស អបលក្ខណ៍ជុំជាតិ

នាថ រំភុករំភួយ ៗ ធ្វើជាឈើចាប់ ក្តៅដើរស្ទើរស្លាប់ ពន់
រលេះសរសៃ ដើរដៃហត់ព្រួយ រំភុករំភួយ រំភើតទួញ
ឱ! ម្ចាស់ឧត្តម ឈើដើរពិតពុំ ទប់ទល់អង្គា ដោយដើរ
យូរលន់ ឈ្មោះបន់នគរ កម្មព្រេងឲ្យឃ្លា ឲ្យឃ្លាតចេញថ្កាត់ ៗ
ព្រះពាជិវង្ស យល់នាងយក្សយន់ ទួញទូលមហាក្សត្រ ស្តេចជាឧ
សូន ខ្ញុំខ្លួនប្រមាត់ ជិតហើយប្អូនរ័ត្ន យើងនំយាត្រា ៗ ស្តេច
ព្រួសយក្ស ថ្នាក់ថ្នមឥតភាក់ ឥតអន់ទយា ស្ពានជាក្សត្រ បេតី
ស្នេហា យាត៍យាសយាត្រា លន់លុះនគរ ៗ ស្តេចដល់ប្រាសាទ
ប្រសើរស្អាតស្អាត នាំនាងចេញចរ គាល់ព្រះបិតា មាតាកុំធរ ពីរ
ក្សត្រត្រេកអរ ដ្បតបុត្រាដល់ ៗ ព្រះសុវណ្ណហង្ស នូវនាងសុរិយេន្ទ
យក្សាកំហល់ ក្រាបថ្វាយបង្គំ ប្រណម្យទសពល ស្អែនស្តេចយន់
យល់ នាងយក្សអស្សុក ៗ ព្រះសុធនរតន៍ បិតាបក្រវត្តិ នូវព្រះ
មាតា សួរសព្វសេចក្តី យល់ស្រីសោភា សួរឋានៈជា ព្រាហ្មណ៍
ពេទ្យឈ្មោះប្រុស ៗ ស្តេចថានេះឯង ក្រឡាតម្តែង ជាព្រាហ្មណ៍
ស្រេចស្រស់ ស្តេចពុំដឹងជា យក្សាអប្រយស ភមគបង្គុស បង្ខុប
ផាយា ៗ ស្តេចអរពេកក្តាត់ អភិសេកបុត្ររ័ត្ន ឲ្យត្រងភាព ទើប
សុវណ្ណហង្ស ពូជពង្សព្រឹទ្ធា លាព្រះបិតា ឋានប្រាសាទរ័ត្ន ៗ គង់នៃន
ក្រឡា ទីននាងយក្សា ជាពីរពង្សក្សត្រ ស្តេចឲ្យស្រីស្នំ បំរើប្រឹទ
ក្តាត់ តាំងការប្រយត្ន័ ប្រគល់វេនគ្នា ៗ មុខងាររួះរៀប គោជ្យក័ស្តុ

របៀប របបឧដា ខ្ទះលើកចូលថ្វាយ ស្រស់ស្រាយម៉ីម្មា ដល់ស្រែ
ថ្វាយគោជន៍ក័ស្តុផល ៗ នាងសុរិយគ្គ័យក្ស ធុំក្លិនមនុស្សម្នុះ
ខ្យណរកកល ចង់សុីអស់ស្រី ស្រដីខ្វាយខ្វល់ គ្នាក៏រវល់ ក
នៅ ៗ ចូលចេញក្រៅថ្កាត់ ហានក្រៅឲ្យស្ងាត់ ឲ្យស្ងៀមមាត់នៅ
ដំរិតអញជាទុក្ខ អផ្សុកពេកក្រូវ បរចេញឲ្យនៅ តែម្នាក់រកៀ ៗ អញ
នៅនេះវៃ កញ្ញាស្រីទាំង ចេញទៅគប់គ្នា ទាំងរយទាំងពាន់ ណាស
ណាន់ត្រៀបត្រា ដំរិតនាងជាយា បណ្តេញចេញក្រៅ ៗ នៅខាងក្រៅ
ម្នាក់ អគ្គុយសំណាក់ ពិតពុំចេញទៅ កញ្ញានាងអសុរី ឈានខ្ទួស
ទៅ ទាំងទ្វារជិតក្រូវ ប្រាណប្រែកាយា ៗ ជាយក្សធំក្រៃ កាច់កាសៅ
ដៃ ចាប់បរិភោគ្គា អស់ឥតសំណល់ ឈាមជាប់ទេណា លិទ្ធលេបមិញ
លុបលាងមុខមាត់ ៗ ផ្ទឹតទឹកស្រេចស្រាប់ ប្រាណប្រែក្លាប់ ពេច
វឹងវិ៉ ជានាងសុរិយគ្គ បញ្ចក្សរស៊ី ល្អល្អះប្រែក្រតី ប្រែកបលក្ខណា ៗ
នាងនាថអសុរី លួងលោមអស់ស្រី សំរិទ្ធស្នេហា មួយថ្ងៃ...
ពុំក្រែងបេស្តា ពុំមានអ្នកណា ដឹងជាយក្សឡើយ ៗ ស្រេចទើបយក្ស
ស្រី បើកទ្វារចេញទ្វី ស្រែកហៅថាវ៉ឺយ អស់គ្នាចេញចាត់ ស្ងួន
ស្ងាត់ព្រងើយ មិនចូលមកឡើយ លើកគោជន៍ចេញក្រៅ ៗ អស់អ្នក
អស់នាង រូតរត់ចូលក្លាង ម៉ីម្មាចូលទៅ លើកបណ្ណាការ គោជនានោះ
ក្រូវ បរចេញមកក្រៅ ពិតពុំស្អាត ៗ ពុំបានចាប់ក្លិក ស្រីផឹកទឹក
ប្រើនក្រៃត្រៀបត្រា ពុំដឹងដល់ស្រី យក្ខិនីប្ដូរ ឡើយស្រីនាំគ្នា គង់

គាល់ច្រើនក្រៃ ៗ

## បទព្រហ្មគីតិ

នឹងថ្លែងថ្លែងបរបា ពីជាយាស្រីរតន៍ថ្ងៃ កេតសុរិយគ្គប្រពៃ កាល អសុរប្រាននាងនាថ ៗ ធ្លាក់ទឹកជ្រាលជ្រៅ នាងស្រីពៅលិចលង់ កាល ណោះវៃទើបនាងនាថ ធ្លាក់ទឹកទើបផុសឡើងហោង ៗ លោក បែកផ្កាត្រែង ខ្ញុំរំពៃងនាងចន្ទ ហិចហែលហៅព្រះបង ខ្ញុំឃ្លាត ឆ្ងាយពុំយល់ឡើយ ៗ នាងទួញទល់ទុក្ខា ទុកជាស្លាប់ទៅហើយ ពុំ ប្រាបដល់គិចឡើយ ជាប្អូនធ្លាក់គង្គា ៗ ទុរាស់ទោសអប្បលក្ខណ៍ រាជាយក្ខទេក្ខរណា និម្មិតអង្គអាត្មា ជាដូនចាស់ទោសអប្រិយ ស្ទុះមក ព្រានអញណា ធ្លាក់ហើយរាំមឃ្លាតខ្ចី ម៉េះរាំប្រែត្រឹយ លួងបញ្ជោត ព្រះរាជា ៗ ទុព្រះអង្គឧត្តម ប្អូនកំខំពេកណាស់ណា ឲ្យរួចរស់ជន្មា បានយល់ព្រះភក្ត្រចមចៅ ៗ លោកបោកមកដល់ ស្ទើរជាប់ខ្សែលិច លង់ទៅ កណ្ដាលទឹកជ្រាលជ្រៅ សមប្អូនក្ស័យនៃជន្មា ៗ ក្រពើ ធ្លាមមករផង ហែលត្រសងក្នុងគង្គា សមខំនាំភក្ត្រា ប្អូនគិតខ្លាចណាស់ ព្រះអង្គ ៗ ទុកម្ទៀរពើព្រៃង ព្រាត់ម្នាក់ឯងមកលិចលង់ ស្លុតស្លាប់ បាត់នៅក្នុង ទឹកទន្លេធំមហិមា ៗ នាងលើកករបង្គំ ទៅព្រះព្រហ្មព្រះ ឥន្ទ្រា គុណកែវរតន៍ថ្ងៃថ្លា សូមជួយខ្ញុំកាលនេះម្ដង ៗ ឯអស់ហ្វូងមច្ឆា ហែលរេកហែបត្រសង ពុំអាចចូលទ្រើសឃ្លង ទៀបព្រះអង្គនាងឡើយ ណា ៗ គេដះបុណ្យបារមី នាងក្សត្រីស្រីកញ្ញា រំជួលដល់មច្ឆា

នាងណើកណាំ ៥០០ ស្នោះ ៗ នាងផាលីកាននៃ ប្រឹកអស់ស្រី ៥០០
នោះ បន្ទាប់សោតនាមឈ្មោះ នាងឧកណាទេវីថៃ ៗ ចុំតបាននៅគោ
ហា កែវរចនាមាសប្រែពៃ ក្នុងទឹកវល់នោះនៃ សុខសប្បាយបរិបូណ៌
បុណ្យ ៗ រំដួលក្នុងទយា នាងធីតាស្រីគេគន់ បង់ចេញ...
ទៅក្រែសាលលេងសប្បាយ ៗ ដម្រេះព្រះកេសា ស្រង់គង្គាទឹទូរថ្ងាយ
តិតស្រែបស្រីគោមគាយ នាងផាលីកានជាបង ៗ បន្ទូលថាហៃស្រី
៥០០ នៃយើងចេញហោង ដម្រេះព្រះកេសផង តន្ត្រីនេះណាប្អូន
ស្រី ៗ អស់នាងស្តាប់ពាបា ព្រមគប់គ្នាស្រេបទេវី ទ្រង់គ្រឿងគ្រប់
ឥន្ទ្រិយ៍ ល្អល្អះដូចស្រីសួគ៌ា ទាំងប្រាំរយដេរដាស កាន់ផ្តិលមាស
ចេញចក វៃហលធ្វង់ព្រះគង្គា ក្បែណាជាលីកានជាបង ទតយល់នាង
សុរិយន្គ ទំហៃហលក្នុងទឹកគ្នាស់ធ្វង់ ជាលីកានទង្វង់ ចូលថ្នាក់ថ្នម
វដយា ៗ ណើកណាំទាំងប្រាំរយ ចូលដេយស្រង់ធីតា ទាំនាងឡើង
ជាក់នា ផ្តេរគង្គាជួបជុំស្រេប ៗ សាកសួរសព្វសេចក្តី ថានាងស្រីស្រស់
សួតសាប់ ប្រែការកល់ដូចម្តេច បានជាហៃហលធ្វង់គង្គា ៗ វនាមនាង
សត្រី នាងឈ្មោះអុំបូរចរតា ប្រាយប្រាប់យើងតាប់ក៏ ទីងបានដឹងអស់
សេចក្តី ៗ នាងស្តាប់អស់ស្រីផង នាងទង់វង់ស្រស់ប្រិមប្រិយ សំពះ
នាងផាលី ប្រាយប្រាប់ពីអតីតា ៗ បពិត្រខ្ញុំប្អូនស្រី ទៅបុរីមុស
ត្រៃមា វនាមខ្ញុំនេះណា ឈ្មោះគេតសុរិយន្គក្សត្រី ៗ ព្រះរៀមរាជ
វរវង្ស សុវណ្ណហង្សជាស្វាមី ជិះសេះហោះចៀវចៃ ទៅនគរព្រះរាជ ៗ

អយ្យកេ[illegible]វធានី ហោះចេញពីនគរ មកតាំងកជរដ្ឋ ឈប់នៅនា

កណ្ដាលព្រៃ ៗ ព្រឹកឡើងរកសេះបាត់ ព្រះមហាក្សត្រសោយសោក

ក្រៃ នាំខ្ញុំដើរកាត់ព្រៃ ផ្លូវឆ្ងាយសល់ពន់ប្រមាណ ៗ លំបាកលំបិន

អន្ត ពីរនាក់ក្នុងព្រៃព្រហ្មសាន លង់លុះក្សត្រប្រធាន នាំខ្ញុំដល់ឆ្នេរគង្គា ៗ

នទីធ្ងន់ទៅ[illegible]ាន ទើបឈប់ខានមាននាវ ដូនតាស់ចោរផក អុំទូកមកសួរ

ដោយសារ ៗ លុះឆ្លងមកជួបដល់ ទីមណ្ឌលទឹកកណ្ដាល ដូនខ្សល់ញុំ

ពេញមា រកើតវេលករលៀបក្រៃ ៗ យាយតាស់ចោរអប្បលក្ខណ៍

ប្រាទម្មា ខ្ញុំកង់ផ្ទៃ ទន្ទេធំនោះនៃ ហៃលស្មើរក្ស័យព្រះជន្មា ៗ បើកុំអស់

អ្នកបង់ [illegible]យពង្វង់ដល់នេះណា សមក្ស័យនៃជន្មា ពុំបានរស់រួបជីវិត ៗ

នាងថ្ងន់ហើយសោយសោក សែនអាមោកសល់សែនទ្វី ទ្រូញទៅព្រះ

ភូមី [illegible]ះ សមប្អូនសួទ្យអាសា ៗ នាងណើកណាំក្សត្រ ស្ដាប់សំដី

ទើបនាងទាថ អាណិតពាក្យពីកាល រងលំបាកលំបិនសល់ ថាប៉ូរ

សួនបណ្ដាប នាងចរបូលក្នុងមណ្ឌល បតចាំព្រះទសពល ក្រៃងសំ

ណាងនាងទៅ ៗ ស្ដេចតាមមករកនាង សុំអ្នកប្អូនគ្នាស្រស់ប្រិមប្រិយ

បានជួបជួនស្វាមី យើងជានារក្សាត្រង់ ៗ កេតសុរិយង្គក្សត្រ ស្ដាប់

សំដីអស់នាងផង ព្រមចិត្តចាំព្រះបង់ នាងសោយសោកពន់ពេកក្រៃ ៗ

អស់នាងណើកណាំយល់ នាងសោកសល់លោមស្រដី កក់ស្រង់ព្រះ

កេសី ស្រេចផាលីកានផាបង់ ៗ ពនាងនាថកញ្ញា អស់ធីតាណើក

ណាំផង ហៃនាងនាថទន្ទង់ ដល់គោហាថានលំនៅ ៗ នាំនាងកេត

សុរិយគ្គ ទតលេងក្នុងស្រែបចេញក្រៅ ឋាង្ហបង្ហាញទៅ ស្ទូងស្រូវ ទៅស្រីមើលក៏ ៗ ត្បូងពេជ្រលេចពន្លក បទុមកកាយមុត្តា ទទឹម នៃបតាក រតន៍រៀងកាយកល់ថ្មក់ថ្មល់ ៗ រតហាកៃរត្នមណី ពេជ្រ សោភីមាសត្បៀថ្លាក់ កន្ត្រាំងក្លាក់ផាក់ ផាំពីភាយពីទ្បូស្រឡះ ៗ និលរត្នរៀងរត្នា ខត្តសុវណ្ណានៃបពេញពាស នាងមើលគន់ដេរដាស ពិតប្រាកដប្រែកបកែ ៗ លុះស្ងាត់ព្រះសុរិយា នាងធីតានាំស្រីថ្ម ចូលបន្ទំប្រថៃព លន់លុះព្រះសុរ្យសែងសារ ៗ នាំនាងលេងគោហា ឲ្យជយាក្មេងគម្លែង សុរិយគ្គទ្រង់កន្ទ្រង់ ពុំមានល្ហៃល្ហើយទយា ៗ

## បទភាកគតិ

យើងនឹងស្រដីអំពីអសុរី កំពលយក្សា នៅសេះអស្សុតរ បររសោភា ឈប់អស់ទេព ប៊ីថ្ងៃប្រាកដ ៗ និកដល់ក្សត្រា ឥស្សូរសិរិសា សត្វថ្ងៃ ពេកក្តាត់ លុះដល់ទេព យក្សានីរពាត់ បន្ទូលសាស័ត្យ សាសង់ទៅថា ៗ ហៃបងអស្សុតរ លុមយើងចេញចរ ទៅតាមក្សត្រា ម៉េះសមព្រះអគ្គ ពីរពង្សសោភា រកពង្ធអស្សុរាហ៍ ឃ្លាឃ្លាតយូរក្រែ ៗ ក្សិណាពងអស្សុតរ ចូលចិត្តចេញចរ ទៅរកក្សត្រថ្ងៃ កាលនោះកំពល អសុរាទិរភ័យ ផ្តាំអស់ មន្ត្រី ពលពាលសេនា ៗ ចូរចាំប្រយ័ត្ន បូរីរមរ្យរត្ន រក្សាស្រុកប្រជា អញទៅតាមក្សត្រ បរគាត់ព្រឹក្សា តែនឹងអស្សុរាហ៍ ឥឡូវនេះថ្វាត់ៗ ស្តេចផ្តាំសេនា ស្រេចហើយយក្សា ទ្រង់គ្រឿងល្អក្តាត់ ព្រះមកុដកង កន់ ទិព្វតន្ទ្រប្រវ៉ាត់ ស្បូរកានពេជ្ររត្ន ក្បឹផ្លែករំហាស៍ ៗ ពាក់ក្រោះ

ក្រោលពេជ្រ រុងរឿងក្បូរក្បាច់ ឆ្លាក់ឆ្លៅរចនា ស្រេចបង់គ្រឿងនៃ
មនោម័យអស្សព្រាហ៍ រតនៈកែវក្រហា បង់ក្រង់សឹងថ្មី ៗ បន្ទៀរឃ្មុំមុខ
ក្បូរក្បាច់សឹងក្អូក មាសមានរស្មី ឆ្លុះឆ្លាក់ត្បូងពេជ្រ រលេចស្រស់
ស្រី ស្រេចហើយអសុរី ចាប់កែវក្រលា ៗ ហៀរហោះប្រៀវប្រែ
កណ្តូសមនោម័យ ហោះនាំយក្សា លឿនលន់ឆ្ងាយសល់ លុះដល់សាលា
ដែលក្សត្រទេវហា ផ្ទំផ្ទុំនិត្យនៅ ៗ លុះចុះចាកដល់ សាលាមណ្ឌល
ពុំយល់ព្រះចៅ កំពលយក្សា រូបហាចូលទៅ រុករកថានក្រៅ សព្វ
ប្រែកដែលង ៗ ពុំយល់ក្សត្រថ្ងៃ ឧបកមនោម័យ ទូញទូលវែងវង ថា
ឱព្រះបាទ នរនាថបក្រាស់បង្រង សមស្តេចទាំងសង ដើរដោយ
ព្រឹក្សា ៗ សត្វប្រេនដេរដាស់ សុទ្ធសឹងរមាស រមាំងខ្មោងខ្លា ដំរី
សារសល់ យន់យល់មនុស្សគ្នា ដាលដេញសោះសា ក្សិណពីរត្តួតតៗ
សមព្រះកិតក័យ ព្រះអង្គក្សិណក្ស័យ ជីវិតបង់បាត់ លែងឃើញព្រះ
សព រកគ្រប់ព្រៃស្ងាត់ ម្តេចឡើយបង់បាត់ ពុំយល់ឡើយណា ៗ
ស្តេចយុត្តសោយសោក សែនសល់អាមោក ញាប់ញ័រអង្គា សម្រាល
សោកស្រេប ស្តែងស្តេចយក្សា មនោម័យនាំគ្នា រត់រកក្សត្រថ្ងៃ ៗ
សព្វដោយព្រឹក្សា ជ្រង់ជ្រោះគោហា ជាប្រាំពីរថ្ងៃ ពុំយល់ព្រះបាទ
នរនាថជៀស្ឋជយ ត្រេចកាត់លេចព្រៃ ដល់ឆ្នេរសាគរ ៗ នឿយ
ណាស់អស្សុរី កណ្តូសមនោម័យ លីលាចុះចរ ស្រង់ព្រះគង្គា យក្សាបវរ
នឹងកពជអស្សុតរ ឈរឈប់សម្រាន្ត ៗ ក្រោមដើមព្រះជ្រៃ គយគន់រំពៃ

មើលសព្វទីឋាន ក្រែងឃើញព្រះបាទ នរនាថប្រធាន នៅនាងកល្យាណ
ជាម្ចាស់សិរសា ៗ នឹងថ្វីនស្រដី អំពីនាងស្រី ណើកណាំធីតា
ពីដូចសត្រី ប្រិមប្រិយសោភា នៅផងជយា ជាលីកានបង ៗ នាំនាង
សុរិយេន្ត លីលារកស្រង់ សព្វថ្ងៃទៅហោង ថ្ងៃនេះឯងណា ជយា
ស្នេហ៍ស្ងួន ណើកណាំចាំងសង បបួលអស់គ្នា ៗ ប្រាំរយបរិសុទ្ធ
ទ្រង់គ្រឿងស្រគត់ ស្រគមលោភា ខ្វះកាន់ផ្ចិតមាស ឧភាសថ្ងៃជា
ហៃហាមធីតា នាងកេតសុរិយន្គ ៗ ដល់ឆ្នេរនទី ពុំឃើញអសុរី ស្រេច
នាងវង្វេង បមទៅជយា ធីតាស្រេចស្រង់ ជម្រះព្រះអង្គ នាគាល
នោះនៃ ៗ នាងខ្វះចូលផុស ព្រះអង្គស្រេចស្រស់ ថ្នាក់ថ្នមបេតី
ខ្វះផុសព្រះបា ទាស្អាតស្រស់ស្រី ឆ្វេងស្ដាំឥតបី ឥតបើមានហ្វូង ៗ
ហេតុស្រឡាញ់ស្រី សុរិយន្គប្រិមប្រិយ ល្អងលោមស្នេហ៍ស្ងួន ឲ្យ
បន្ទោទុក្ខ សាន្តសុខទៅហោង នាងគិតព្រះបង ពិតពុំសប្បាយ ៗ
កាលនោះកំពល យក្សាមើលឃល់ នាងនាថជាក់ហើយ ជាបងអស្ស-
ពាហ៍ មើលរ៉ាបងអើយ ម្ចាស់ឃើងឯងហើយ មើលឲ្យប្រាកដ ៗ
សេះថាមែនហើយ យក្សាបងអើយ ម្តេចបាត់ចក្រវត្តិ ឃើញតែណើក
ណាំ ហោមចាំច្រើនក្តាត់ បម្រើស្រីរតន៍ ផុសខាត់បាតា ៗ កញ្ញា
នោះកំពល រួតរត់ខ្វាយខ្វល់ ពីនាយសេះសា មនោម័យតាមដល់ យង់
យល់ជយា យក្សដល់វន្ទា ក្រាបក្រោមព្រះបាទ ៗ ឯអស់ណើក
ណាំ គិតភ័យពិតពុំ ទល់ទុក្ខអង្គអត្ត ខ្វាចយក្សអសុរ មុជមុល

សង្កាត សង្កេតខ្មីឃ្មាត រួតរត់ពួនព្រៃ ៗ ខ្លះមុជក្នុងទឹក ជ្រាល ជ្រៅពទ្ទឹក ខ្លះគន់វៃព ជ្រកជ្រោះសិលា ប្រាថ្នាខ្លាចក្ស័យ គត់ ស្មុតគិតភ័យ ស្រែកយំរកគ្នា ៗ កាលនោះអសុរី យង់យល់អស់ ស្រី ណើកណាំនោះណា គិតភ័យខ្លាចយក្ស ក្មារក្មាក់នាំគ្នា រត់ រត់លីលា ជ្រុលជ្រកទីទៃ ៗ នាងស្រែកហៅថា បងអើយមកក៏ កុំ រត់ជ្រកព្រៃ ខ្លាចអ្វីយក្សខ្ញុំ នាងកុំសង្ស័យ យក្សតាមខ្ញុំនៃ មក ពីភាព ៗ នាងផាលីកាន ព្ទនាងសោភ័ណ ត្រាស់ហៅប្អោះណា នាងខ្លាចយក្សយង់ ប្រៀបប្រុងអាត្មា ឈរឈប់វេក មៀងមើលមុង ៗ ៗ កញ្ញាណាស្តេចយក្សា បន្ទូលហៅថា ហៃអស់នាងផង បបួលគ្នាមក ពីប្រកផ្លង កុំខ្លាចឡើយហោង ចូលមកម្នីម្នា ៗ យើងជាខ្ញុំបាទ បរិចារិកនាងនាថ ជាម្ចាស់សិរសា មកតាមព្រះអគ្គ ពីរពង្សទេណា ទើបជួបកាលគ្រា ឥឡូវនេះនៃ ៗ នាងនាថផាលី ឱវន្ទទៅ ស្តាប់ពាក្យ អសុរី ហើយហៅនាងនាថ ត្រអាលចូលខ្មី ហាហៅអស់ស្រី ប្រាំរយ អគ្គា ៗ ជួបចូលស្រែចស្រាប់ ផាលីកានប្រាប់ កំពលយក្សា បង អីយយើងរើស ក្សត្រិកញ្ញា ហែលក្នុងគង្គា ស្ទើរក្ស័យជីវី ៗ យក មករក្សា លួងលោមជយា ជារាជមហេសី ព្រះសុវណ្ណហង្ស ពូជពង្ស គោធី ពុំឲ្យទៅ អាក់អន់ចិន្តា ៗ បើសំណាងមាន យើងផងនឹង បាន ពឹងពាក់ជយា តទៅណាបង កុំបង់ទោសា យើងខ្លាចណាស់ ណា បងយក្សអសុរី ៗ ព្រះបាទអសុរី ស្តាប់ពាក្យអស់ស្រី បន្ទូល

ថាហៃ អស់អ្នកមានគុណ អនន្តពេកក្រៃ ទុកស្មើដីទី បង្កើតហោង
ណា ៗ បើកុំអ្នកស្រង់ ម្ចាស់ខ្ញុំលិចលង់ នៅក្នុងគង្គា អសារសូន្យ
សល់ ពុំយល់កត្រ្ដា គុណអ្នកមហិមា ឥតអ្វីផ្ទឹមបាន ៗ ស្រេចហើយ
ក្សត្រិ សាកសួរម្នាមៃ ហៃបងអសុរយាន ហេតុម្ដេចបងចាក លះ
លាកចោលប្អូន ក្សត្រារុកពន រកសព្វមគ្គា ៗ ពុំយល់បងឡើយ
ស្ដេចសោកពុំស្បើយ សន្ធប់នៅនា លុះភ្ញារភ្ញាក់ប្រាណ ក្សត្រក្សាន្ត
លិលា នាំអញ្ញយាត្រា លំបាកពេកក្រៃ ៗ សេះស្ដាប់នាងនាថ
សេះទូលអស់អាថ៌ អសុរចង្រៃ ប៉ងទឹងពិឃាត ព្រះបាទដៀស្ឌ័យ
ខ្ញុំច្បាំងចាញ់ដៃ អសុរយក្ស ៗ វាចាប់ខ្ញុំបាន ជិះហោះដល់ឋាន
កំពលយក្ស រីស្ដេចអសុរ កំពលអាសុរា ទូលនាងជយា បពិត្រ
ម្ចាស់ថ្លៃ ៗ វិរុលមេកម្មា ចិត្តពោរឫស្យា វាជិះមនោម័យ ខ្ញុំតាម
ខ្ឃាត ពីឃាតវាក្ស័យ ឈប់ខានបីថ្ងៃ ជ្រុតឈឺអគ្គា ៗ ទើបលី
លាមក សាលារត់រក ពុំឃើញក្សត្រា ដើរកាត់ក្នុងព្រៃ ឆ្ងាយក្រៃ
មហិមា ប្រាំពីរខេរា ទើបដល់នេះថ្វាត់ ៗ បពិត្រជយា ព្រះរៀម
រាជា ស្ដេចទៅណាបាត់ ឃើញតែក្សត្រិ ស្រស់ស្រីរូបរត្ន ប្រាយ
ប្រាប់ខ្ញុំថ្វាត់ ឲ្យដឹងដើមដាន ៗ ក្សត្រិវង្សក្រូល ស្ដាប់យក្សទូល
សាកសួរពតិមាន នាងនាថអួលអន់ ប្រាប់យក្សស្មោះស្មាន ដូចដើម
និទាន ទាល់ទើបច្នេះណា ៗ កាលដូនចាស់យក្ស ចោរដួអប្យល-
ក្សណ៍ ព្រាននាងធីតា ធ្លាក់ក្នុងទឹកស្មោះ កាលនោះឯងណា ជួប

នឹងធីតា ចូលស្រង់ទេវី ៗ ព្រាយព្រាប់កម្ពល ហើយនឹងទប់ទល់
ពុំបានក្សត្រី សោយសោកព្រះបង់ វង្វេងទុក្ខថ្មី ស្មើរក្ស័យជីវី ជីវិត
មរណា ៗ លុះសោកស្រេចស្រាល សំណោះសំណាល សំនួរបរ
៣ ស្រេចទើបកំពល អសុរយក្ស សុំនាងធីតា នឹងនាំយកទៅ ៗ
ថ្វាយព្រះរាជា ឥន្ទ្រវនេះណា ឲ្យដល់លំនៅ នគរអយ្យវត្ត ទើប
ក្សត្របមទៅ បន្ទូលត្រាស់ទៅ នឹងអស់មេធា បពិត្រអ្នកមាន គុណ
គាប់ប្រធាន ឥន្ទ្រវនេះណា ខ្ញុំសុំនាងនាថ ត្រកាលសោភា យក
ទៅភាព ថ្វាយព្រះបក្រិ ៗ បើបានជួបស្រេច សុំព្រះអង្គស្តេច លី
លាមកខ្ញុំ សងគុណនាងនាថ នាកាលនោះនៃ សូមអ្នកមេត្រី បើក
ឲ្យខ្ញុំ ៗ ឯនាងផាលី កានទៅនាងស្រី ទុក់ន៍ស្នេហ៍ស្និទ្ធ ស្តាប់ពាក្យ
កំពល អសុរសាស័ព្ទ សុំនាងស្រីរត្ន យកទៅនគរ ៗ នាងព្រិម
ចិន្តា ពុំឃាត់ជយា ឲ្យស្តេចចេញចរ តាមព្រះស្វាមី អស់ស្រីគក់គ
ទុក់ណាស់ទ្រី ស្រណោះធីតា ៗ ទ្រង់ទួញកន្សែង ឧបនទ្ធាប់វែង សបក្រាយ
ផង់គ្នា ឥន្ទ្រវបង់បាត់ សូន្យស្វាត់ពា អស់យើងតែងបា រម្មណ៍គិត
សព្វថ្ងៃ ៗ នាងកេតសុរិយេន្ទ្រ ទ្រង់យល់អស់អង្គ ស្រណោះស្រីថ្ងៃ
ផលនេត្រសស្រោក ហូរធ្លាក់ដល់ដី ពិលាបឥតបី ឥតបើសាស័ព្ទ ៗ
នាងនាថថ្ងួញថា ឱបាបអស្ចារ្យ ឯងឲ្យព្រាសព្រាត់ បានជួបជយា
ធីតាប្រវត្ត មានគុណគាណិត គាសូរស្រោចស្រង់ ៗ រស់រួចឡើងថ្វាត់
ឥន្ទ្រវម្តេចព្រាត់ ព្រាសចេញបោះបង់ ឱអ្នកមានគុណ ទុក្ខធ្ងន់លើស

លង់ ផ្សិតខ្លួនបោះបង់ បោះបាត់បំបែង ៗ នាងជាលីកាន ទឹងនាង
ទុកាន់ សោយសោកលើសលែង លួងស្រីសុរិយគ្គ ទុបអង្គថ្លាថ្លៃ
កុំនាងកន្ទ្យេង ពិលាបសោកា ៗ បងគ្មានអ្វីនៃ ផ្តឹលមាសប្រពៃ
នាងយកទៅជា គាងតួយើងបង គ្រប់គ្រងរក្សា សោះស្រណោះគ្នា
ណានាងប្អូនស្រី ៗ នាងឆ្លើយវិញថា អ្នកបងស្នេហា អាសូរខ្ញុំនៃ
អ្នកឲ្យផ្តឹលមាស ទុកាសប្រពៃ អរគុណណាស់នៃ ណាស់ទឹងស្កា ៗ
ផ្សិតខ្ញុំពុំតាន់ សងគុណជាក់ស្រាន់ ដូចដោយវាចា បើខ្ញុំបានដល់
មណ្ឌលក្សត្រា ជួបគ្នាហើយណា ទឹងវិលវិញខ្ញុំ ៗ សងគុណអ្នកបង
ដូចគេបំណង បំណាច់មេត្រី សុំខ្ញុំទទួល ផ្តឹលមាសប្រពៃ ដឹកនាំ
ប្រិមប្រិយ ព្រមព្រះចិន្តា ៗ ទើបស្តេចកំពល យល់នាងសោកសល់
សំណេះចរចា ទូលទៅណើកណាំ ទាំង៩០០ ថា កុំអ្នកសោកា
ក្រេមក្រាន្តព្រះទ័យ ៗ ខ្ញុំទៅដល់ថ្នាត់ ជួបទឹងមហាក្សត្រ ហើយ
ខ្ញុំវិលវៃ ត្រឡប់វិញឆាប់ ប្រញាប់វៃ ៗ កុំអ្នករវៃ គន់គិតឡើយណា ៗ
ណើកណាំស្រស់ស្រី សង់ស័ព្ទសំដី ហៃបងយក្សា ដល់ហើយទូល
ក្សត្រ បក្រវត្តថ្លៃថ្លា ឲ្យជោបទយា ពីយើងផងនៃ ៗ នាងគេត
សុរិយគ្គ កំពូលជួញជគ្គ លើកករទ្ទី លានាងណើកណាំ ប្រាំរយ
ឥន្ទ្រីយ ទៀងគង់មនោម័យ ហិចហោះវេហាស៍ ៗ ខ្ពង់ខ្ពស់ត្រដែត
ត្រដឹមហាក់ហែត ឥន្ទ្រព្រហ្មលីលា រស្មីភ្លឺច្បាស់ ស្រឡះបេហា
ណើកណាំពល់គ្នា សាធុការអឹងកង ៗ គោតស្ងែងបារមី នាងនាថ

ពេកក្រៃ ផ្ដែផ្ដាំទង់វង់ មាសអើយវិលធាប់ ត្រឡប់កាន់បង់ ទទឹង
នាងហោង ពិតពុំមានគ្រប់ ៗ កំពលយក្សា ហោះហែជយា លឿន
លន់ស្រាប់ស្រេច លុះដល់អយុទ្រគន់ ព្រាកជរំពេច សេះសាគហោះ
ហិច ទៀបនាធានី ៗ ឈប់នៅសាលា ខាងក្រៅគាព ស្រេចអសុរី
ក្រាបទូលនាងនាថ ត្រកាលប្រិមប្រិយ បពិត្រក្សត្រិ បងចាំនៅនាៗ
សាលានេះនៃ បងឹកជមនោម័យ ចូរចាំរក្សា ខ្ញុំនឹងចូលគាល់ មើល
កលក្សត្រា នឹងមហាអសុក ប្រការដូចម្ដេច ៗ រូបខ្ញុំលីលា អញ្ជើញ
ធីតា ចូលទៅគាល់ស្ដេច ក្សាកក្សិណក្សត្រិ ប្រិមប្រិយសួតសេប
ព្រមព្រះទ័យស្រេច ឲ្យយក្សបរបួល ៗ កំពលក្រាបលា ក្សត្រីកញ្ញា
ត្រេចត្រង់ពុំយូរ ដល់ព្រះពដា ក្សត្រីវង្សុ លួនលបចរបួល បង្គំដា ៗ

## បទពំនោល

ព្រះសុវណ្ណហង្សថ្វាថ្ងៃ ទតយល់អសុរី ឡើងគាល់ព្រះបាទ
ក្សត្រា ៗ មានព្រះបន្ទូលទៅថា កំពលយក្សា មានហេតុប្រការ
គល់អ្វី ៗ នគរបវរបុរី មានហេតុនឹងអ្វី ព្រះស្ដេចចូលមកវន្ទា ៗ
ចូរប្រាប់យើងធាប់រួសរ៉ា សត្រូវឯណា ឬមួយសាន្តសុខសប្បាយ ៗ
ស្ដេចថ្វៃប្រាប់ថាយក្សកាយ យើងមកពីនាយ លំបាកលំបិនពេកក្រៃ ៗ
ជិះសេះហោះហៀវហៀវហែ នាងនាថស្រីថ្វៃ សន្ទប់ស៊ើរក្បៀយជន្នា ៗ
គាប់ឃើញសាលានៅនា ព្រៃព្រឹក្សអធ្វា បរចុះផ្អូលក់នៅនៃ ៗ ភ្ញាក់
ឡើងរកពជមនោម័យ នៅសាលាជ័យ អញរកពុំឃើញឡើយណា ៗ

នាំនាងចរចុះយាត្រា យូរថ្ងៃគាត់ណា ក្បៀងផ្គរផ្ការពុំគិត ។ នឿយ
ណាស់ល្ហិតល្ហៃព្រួយចិត្ត ត្រេចដើរពុំគិត ពុំព្រួយក្នុងព្រះកាយា ។ នាង
យក្សក្រើកក្រួងសួរថា ចុះព្រះមាតា បានសុខឬទេណាបង ។ ជ្រុតខ្ញុំ
ពុំចាំឡើយហោង ជ្រិតឃ្លាតយូរផង ព្រះបងនាំត្រេចព្រឹក្សា ។ ខំ
ឆ្ងើយម្ទោះហើយម្នីម្នា ដាក់មុខឆ្ងើជា ករកើះករកេះមិនបាំង ។ ព្រះ
ពៅពិសត្វស្លាប់កាំង យល់ក្រុងក្រោធខ្លាំង រលាំងរលះប្រាប់ប្រាយ ។
ថាបងកំពលបុទ្ធិសាយ សុរិយង្គឆោមឆាយ នេះហើយជាស្តេចយក្សា ។
ជ្រិតឃ្លាតព្រាត់ពីនគរ លំបាកច្រើនគ្រា វេទ្ធនក្រុបក្តាំងស្វាវតី ។
កាលហោះផ្ទុកផ្ទោះប្រៀវប្រែ សន្ធប់យូរក្រែ ស្មើរក្សយជីវិតមរណា ។
ចុះដើរកើតព្រួយអង្គា តើបពះនឹងខ្ញា រមាំងរមាសច្រើនក្រៃ ។ គិតតាំង
ស្រុកស្ទាំងទេត្រៃនៃ បង់បាត់ស្វាវតី វេទ្ធនាវិលវល់ក្តាំងក្តាត់ ។ លុះ
ដល់ឥឡូវនេះបាត់ ស្វាវតីស្រីរត្ន ពុំដឹងពុំដូចសព្វគ្រា ។ កាលនោះឯ
ក្រុងយក្សា ស្តាប់ព្រះឱក្កា ព្រះបាទព្រះអង្គជៀស្ន័យ ។ ពុំប្រាបថា
យក្សទេនៃ ក្រឡាខ្លួនវៃ ស្មានជាសុរិយង្គពន្ធក ។ បើប្ញោះគួរអញ
ទៅយក នាងនាថនោះមក ឲ្យដឹងដំណើរសេចក្តី ។ គិតស្រេចក្រុង
យក្សអសុរ ទូលព្រះចក្រី បពិត្រសូមប្រាបទយា ។ ខ្ញុំនឹងទៅយក
ស្ងួនភ្ងា មកថ្វាយពជា បានប្រាបសេចក្តីជាមួង ។ ឲ្យឃើញពិតៗមែន
ហោង សូមក្សត្របក្រសប្បង ទង់ប្រាបក្រោមល្អងធុលី ។ ទូលស្រេចក្រុង
យក្សបរលើ លាពីកុម ចរចុះតម្រង់ទៅហើយ សំដៅពុំមានឈប់ឡើយ

ទៅយកត្រាណត្រើយ នឹមនួនទេពកញ្ញា ។

## បទភាកគតិ

ពំលន់ដល់ស្រេច ក្សណនោះសម្ដេច សុរិយគ្គធីតា មានសុរណ្ណី ប្រឹមប្រិយសួរថា បងឃើញក្សត្រា នៅហ្នឹងឬអ្វី ។ ក្រុងយក្សគោរព លើកព្រមាមទាំងដប់ បង្គំស្រស់ស្រី សូមព្រះនាងប្រាប ពីអគ្គនរបតី នៅទីឯយក្ខិនី បានសុខសប្បាយ ។ ខ្ញុំទៅបានជួប នឹងអគ្គបមកព មានបុទ្ធីសាយ នឹងនាងយក្សស្រី ដែលជាក្មួនក្លាយ ខ្ញុំមើលពីឆ្ងាយ ស្គាល់យក្សប្រាកដ ។ ខ្ញុំទូលសព្វហើយ ទៅព្រះត្រាណត្រើយ មិនមានកំណត់ ឲ្យខ្ញុំមកយក ម្ចាស់ជាប្រាកដ ចូលទៅឋានថិត ឲ្យបានដឹងការ ។ ហេតុនេះសូមយាង កុំយូរនាំល្អៀង នឹងព្រះឧត្ការ ឆាប់បានទៅដល់ លោកពិនិត្យអាថ៌ ប្រុងដោយបញ្ញា ប្រាប់ក្មួនព្រះទ័យ ។ ក្សណនោះធីតា បានស្ដាប់យក្សា ទន់ប្រែញាប់វៃ ឡើងគង់អស់ត្រេរ យក្សបរពីព្រៃ នាំចូលក្រុងជ័យ ឥតមានមួហ្ន ។ បានដល់ហើយណា ក្រុងយក្សអាសុក នាំយាងជាម្ដង ឡើងដល់ប្រាសាទ យ៉ាងស្អាតហើយហោង ទូលក្សត្រច្បាស់ប្រង ទតវរក្សត្រិ ។ ស្ដេចបានយល់ជាក់ មើលទៅពីរនាក់ ស្រស់កល្យាណី រូបភាពដូចគ្នា តែស្គាល់ក្មួកស្រី ក្មួកយក្សចង្រៃ ក្រហមមហិមា ។ ប៉ុន្តែចង់ដឹង នៅកិច្ចផ្សេង ៗ ឧបាយមាយា ទើបមានឧត្ការ សាសព្ធពណ៌នា អើស្រស់សោភា ទាំងពីរនេតឆាយ ។

នាងកេតសុរិយេន្ទ រូបទាំងពីរពង្ស ណាមួយក្លែងក្លាយ បើតាមចិត្តបង
យកទាំងពីរកាយ គ្រាន់ជាសប្បាយ មួយឆ្វេងមួយស្តាំ ៗ ស្តីនេះឯង
នឹង បើពិតទើបដឹង គិតគូកលចំណាំ បើយក្សប្រាកដ អន្ទុយប្រចាំ
គ្មានត្អើយស្រស្រាំ តបទឹងបត្រី ៗ ឯកេតសុរិយេន្ទ នាងមានតូជពង្ស
ស្រស់កល្យាណី នាងបានស្តាប់ជាក់ ប្រត្យក្សស្វាមី ទឹកនេត្រនាងស្រី
ហូរហើយឆ្លើយថា ៗ បពិត្រព្រះអង្គ សូមជ្រាបក្រោមល្អង ពីខ្ញុំនេះ
ណា ពិតជាមហេសី កូនអគ្គចិត្រា ត្រូវជាបិតា ប្រាកដជាម្តង ៗ
មីមួយនេះណា វាជាយក្សា ប្រាកដហើយហោង វាក្លែងកាយា ជាដូច
ឥតហ្មង ឲ្យបានឃើញធ្លង សមុទ្រផលស័យ ៗ ហើយវាច្រានខ្ញុំ
នៃខ្ញុំលបង្គំ ប៉ងឲ្យក្សិណក្ស័យ ប៉ុន្តែដោយបុណ្យ បានសាងក្រាស់ក្រៃ
ដូចណីកណាំនៃ គេយកអាសារ ៗ សូមជ្រាបក្រោមល្អង បពិត្រ
ម្ចាស់បង សូមទ្រង់មេត្តា ប្អូនជាមហេសី ហើយព្រះភស្តា ឥតមាន
ក្រឡា ខ្ញុំទេម្ចាស់ស្ងួន ៗ នាងក្តៅនឹងមី យក្សនៅក្នុងទី ញ័រ
ព្រះអង្គខ្លួន ទើបដេរទៅថា មេចោរលាក់ខ្លួន ម្តេចហ៊ានធ្វើតួន ហ៊ាន
ប្រានខ្លួនអញ ៗ មកក្នុងអាត្មា ហើយធ្វើរូបា ឲ្យក្រៃស្រឡាញ់
ធ្វើដូចរូបភាព នៃរបស់អញ មេចោរគេបាញ់ កណ្តាលខែចែត្រ ៗ
មេចោរគេកាប់ ពូជយក្សខុសច្បាប់ រកស៊ីដូចប្រេត ឥឡូវក្នុងកាយ
មកធ្វើខុសបែប ហ៊ានមកលួចសេព នឹងព្រះស្វាមី ៗ ខ្លួនឯងនេះ
ណា សមយកភស្តា តែហ្មងដីរ មិនគួរយកមនុស្ស មិនសមបើបី មេចោ

ខេនី ស្រីចិត្តសាមាន្យ ។ ខេនីស្រីយក្ស សឹងបានស្តាប់ជាក់ ទើបឆ្លើយដោយស្មាន ក្រែងអង្គកុធរ ទ្រង់ប្រណីប្រាណ ទើបគបកល្យាណ ដោយពាក្យទ្រគោះ ។ នៃហង់ជាយក្ស ម្តេចមើលមិនជាក់ ហ៊ានមកចង់ឈ្មោះ ហ៊ានមកបង្អាប់ ត្រកូលចាំរស់ គ្មានដឹងបំពោះ ចេះតែពោលទៅ ។ នាងកេតសុរិយង្គ ក្តៅណាស់ញ័រអង្គ ព្រះភក្ត្រហ្មង់សៅ ថាឃើ! មីក្លី មិនគិតឲ្យជ្រៅ តិចមិនបាននៅ កើតជាយក្សទៀត ។ នៃបង់សេនី ស្គាល់ទេយក្សស្រី ប្រាកដមើលមាឌ មាត់ស្មុយដូចខ្មោច នៅព្រះនរនាថ ស្រឡាញ់ណាទៀត ទុកធ្វើស្តាំឆ្វេង ។ ស្តេចប្រាប ឆ្លើយថា ហៃដួងសុដា សូមប្អូនលើកលែង បងដឹងហើយស្រី កុំប្អូនចំបែង បងនឹងចាត់ចែង ឲ្យប្អូនបានដឹង ។ ឯនាងខេនី បានស្តាប់សំដី ក្សត្រជាដំណឹង ថាខ្លួនអញនេះ តាំងគិតរំពឹង ឥឡូវក្សត្រដឹង ជាអង្គយក្សស្រី ។ បើទោះក្លែងខ្លួន ឲ្យបានបំនួន នឹងគិតប៉ោះខ្ចី ទៅលំនៅឋាន ឲ្យដូចប្រក្រតី កុំឲ្យក្សិណក្ស័យ ដូចចិត្តប្រាថ្នា ។ គិតភ្លាមក្លែងប្រាណ យ៉ាងធំបំណាន ដូចដើមធម្មតា ហោះភ្លាមមិនយូរ ប្រឹងអស់គាថា ខ្លាចក្រុងយក្សា ដេញតាមខ្លួនទៅ ។

## បទពាក្យ៧

កាលនោះសុរិយង្គស្រស់ប្រិមប្រិយ៍ បានឃើញខេនីហោះលឿន ស្មៅ មួហ្មងគង់ចិត្តព្រះទ័យក្តៅ ទើបហៅសេនីថាហៃបង ។ ទៅតាមមួលកខ្មោចមីយក្ស ឲ្យបានឃើញជាក់ពេលនេះម្តង សម្លាប់ឲ្យ

ហើយកុំសៅហ្មង យក្សពុះហោះផ្គងតាមខេទី ៗ ប្រឹងហោះតាមនាង
យក្សសាមាន្យ មិនយូរប៉ុន្មានក៏តាន់ទី ស្រែកថាវ៉ៃហាងហោះធ្វើអ្វី
បំផាក្សត្រិសុរិយគ្គហើយ ៗ ផាអគ្គមហេសីសុវណ្ណហង្ស បើឯងកុំ
ហោះណាហងអើយ យកអញធ្វើប្តីក្រែងបានស្បៀយ ចូរឈប់នៅ
ឡើយកុំយូរយារ ៗ នាងយក្សភ្ញាក់ខ្លួនទើបធ្លើយទៅ វ៉ៃអាកំឡោកុំ
ពណ៌នា អញមិនមេត្រីមេអគ្គា ស្ទុំសូន្យផ្ទាក្ខងពេលហ្នឹង ៗ ក្រុង
យក្សស្លាប់ផាក់ញ័រកាយ ក៏រកត្រើយដោយចិត្តខឹង ស្ទុះទៅសំពង
ផតដំណឹង ត្រូវកញ្ចឹងកយក្សខេទី ៗ សូន្យផុនជីវិតពិតពេលនោះ
ផតរស់ដោយមិនស្ទូវបេះអ្វី ក្រុងយក្សទុនកាត់យកសិរសី ហោះខ្ទីនាំ
មកចូលវង្គាន ៗ កាន់ក្បាលយកមកថ្វាយចមភព គោរពដោយគួរ
ដល់ក្សត្រក្សត្ត ស្តេចទតញញឹមជឹងថាបាន ក្បាលមេសាមាន្យមក
ហើយនៃ នាងកេតសុរិយគ្គទ្រង់កន្សែង ថ្វាថ្ងៃនេះរៀបរាប់កាលមានភ័យ
ថ្វាយដល់ព្រះមុនិន្ទួចមកពាក្រៃ ដូចមានវិស្ស័យខាងដើមឃ្លា ៗ រៀប
រាប់កាលពួកនាងណើកណាំ ដោយកម្មបានជួបស្រស់ពុំផា នាំនាង
ហែលថ្កូងត្រៃយគ្គា បានរួចផុទ្ធាដោយការពិត ៗ នាងផាលីកាន
ស្រីផាបង នាំនាងហែលច្នងរួចភ័យកិត ទី ២ ណើកណាំស្រស់វរមិត្រ
នាំដាក់ឋានបំតបានទិត្យនៅ ៗ រាប់រៀបបានមកជួបសេនី ចក្រី
អាណិតដល់ស្រីពៅ ធ្លើយថាហៃប្អូនកុំសោកសៅ ធោមធ្ទោបនឹមិនដឹង
កាយា ៗ ស្នាទផាប្អូនឯងរូបតតខ្មោះ ឥតមានខុសសោះទេកញ្ញា បង

ស្មានជាប្អូនមិនមុសា សូមនាងមេត្តាមកដល់ប្តី ។ បើបងដឹងជាក់មិន ទុកទេ ដូចស្រស់មាសមេដឹងចក្រ ព្យាញ់យក្សស្លាប់គរពេញផែនដី តែ នេះកម្មស្រីណាមាសបង ។ ស្ដីហើយបីបើបស្រស់ឆោមឆាយ អង្អែល អស់កាយឥតមានហ្មង នាងក៏អាណិតក្សត្រប្រាស់ប្រុង ស្នេហ៍ស្នងឥត មានគូបព្រះទ័យ ។ អស្សុតរបង្គំទូលថ្វាថ្ងៃ យាមព្រះគម្ពង់នៅក្នុង ព្រៃ វិរុឡមេឃសណ្ដំព្រះជៀស្ឋ័យ ក្នុងពេលនោះនៃដោយការពិត ។ ព្រមបានសម្លាប់យក្សនោះឯង ថ្វាយព្រះគម្ពង់ជ្រាបការកិច្ច កំពលសេ-នាថ្វាយពិនិត្យ ហោះរកអង្គស្ដេចដួបស្រស់ស្រី ។ រាប់រៀបសាសព្វ គ្រប់កន្ទង់ ហើយទ្រង់កន្សែងអង្គចក្រ អាណិតសេនាគលព្រាណី ឥត បីសោកាតាំងអស់នៅ ។ រួចហើយសម្ដេចចមនរិន្ទ ប្រាប់ប្អូនមាសអ្អិន ស្រស់ពាលពៅ ថាប្អូនឆោមឆាយយើងកុំនៅ ទីឯទៅបង្គំព្រះបិតា ។ ឲ្យលោកបានជ្រាបកិច្ចការកល ដែលមានយោបល់ទូលក្សត្រា គិត ក្វាមនាំនាងបរយាត្រា ប្រាសាទថ្ងៃថ្វាដូចបំណាង ។ ដល់ហើយចុន កាយថ្វាយបង្គំ ដល់ក្សត្រឧត្តមនៃឆោមល្អង បពិត្រព្រះគុណបុណ្យ បម្រង់ ពេលនេះឯងម្ដងប្អូនឆោមឆាយ ។ លើកមុនខ្ញុំនាំវេទ្ទា ដល់ ព្រះរាជាមកដល់កាយ នាងនោះជាយក្សស្រីក្លែងក្លាយ នេះពិតជាកាយ កេតសុរិយង្គ ។ ស្ដេចស្ដាប់ថាបុះនាងស្រីមុន ដែលល្អលើសលន់មាន រូបទ្រង់ យក្សទេប្តីដែលនៅគង់ ខាងក្នុងប្រាសាទនោះប្រាកដ ។ ស្ដេចស្ដាប់សំដីព្រះបិតា ទូលរាប់កិច្ចការតាមបែបបទ ដូចខាងដើម

ឃ្លាដាសន្តតិ ចមមកុដបានជ្រាបសព្វសញ្ញី ៗ កំឲ្យអមាត្យក្រុមសេនា សង់រោងរៀបការស្រស់នារី អភិសេកឆោមឆាយនាងទេវី នឹងអង្គព្រះមុនី រត្នកល្យាណ ៗ ព្រះបាទសុធនរតន៍ប្រពៃ ឲ្យរាស្ត្រផងនៃចូលមក ឋាន អប់រំជួយអង្គព្រះក្ស័ត្រក្សាន្ត អភិសេកឲ្យបានជាស្តេចចក្រ ៗ គ្រានោះនាហ៊ឹនមុខមន្ត្រី រៀបរោងឆាប់ឆ្វីច្រើនអនេគ្យ ធ្វើមិនមានយូរ ដោយរួមរ័ក្យ ឡើងទូលទ្រង់លក្ខណ៍តាមការពិត ៗ ដល់ហើយ បង្គំដោយសួស្តី សូមទូលម្ចាស់ថ្ងៃដោយពិនិត្យ ធ្វើរួចអស់ហើយម្ចាស់ ជីវិត ទ្រង់គិតយ៉ាងណាតាមព្រះទ័យ ៗ ព្រះអង្គបានស្តាប់សេនី ទូល យ៉ាងស្រួលចាត់ចែងគ្រឿងទីទៃ បរិក្ខារទាំងឡាយរំពេចវៃ ក្នុង ពេលនោះនៃច្រើនឥតហ្មង ៗ ស្តេចឲ្យមហេសីសុចិត្រា គាត់តែង កញ្ញានិមន្តនល្អង នាងកេតសុរិយង្គស្រីទង្វង ខាងស្តេចទំនងមក បុត្រា ៗ ឯនាងសុចិត្រាកល្យាណី មករៀបឲ្យស្រីបុត្រប្រសា យ៉ាង ល្អប្រពៃផុតកញ្ញា នៅក្នុងវង្សាគ្មានដូចទេ ៗ រៀបចំពាក់តែងមាស សុវណ្ណ ប្រៀបដូចព្រះចន្ទបូរថេរ មើលសមគ្មានខ្ចោះពីបុព្វេ មាស មេស្នេហ៍បុត្រប្រសាពេក ៗ កំរៀបដង្ហែចេញរោងជ័យ ក្សត្រថ្ងៃ រង់ចាំតែឆោមឯក ខាងប្រុសរៀបរួចច្រើនអនេក ដល់ហើយមិនបែក គ្នាផ្ទឹមខ្ចី ៗ ហើយនិមន្តសង្ឃជយន្តោ ហួសដល់ពហូកាត់ខ្ចី ៗ រួចក្លាយ រាយគង់តូរ្យតន្ត្រី គឺថ្វាយសួស្តីដល់ព្រះអង្គ ៗ រាស្ត្រលេងខាង លៀងច្រើនដេរដាស គប់សាសន៍ថ្វាយដល់ក្សត្របញ្ចង្គ ៧ ទេពរួចជា

ម្ដង ឥតមានមួហ្មងក្នុងរដ្ឋា ៗ បានធ្វើជាស្ដេចធំអនគ្ឃ អនេកស្ដេចចក្រពេញអស្ចារ្យ រាស្ត្រផងសប្បាយដោយបុណ្យបារមីក្សត្រាព្រះបរម ៗ តែងចេញចុងរាំងមើលរាស្ត្ររដ្ឋ សន្តតបានសុខយ៉ាងឧត្ដម នៅជាយូរខែថ្ងៃនិងឆ្នាំ នាងនាថចាំផ្គាប់ព្រះបមកត ៗ សមយេពេល យប់អស្ដង្គត នាងកញ្ញារតន៍ផ្ទំក្រោមម្លប់ និងអគ្គស្វាមីរាត្រីគ្រប់ ពុំមានឈរឈប់ពេលណាឡើយ ៗ យប់នោះនាងផ្ទំមិនបេះលក់ នឹកក្តុកដល់អគ្គិត្រីត្រាណាត្រើយ ដែលយោងស្រង់ខ្លួនពេលនោះហើយ មិនគួរកន្ដើយបំភ្លេចគុណ ៗ នាងនឹកកំសត់ទឹកនេត្រព្រោក ធ្លាក់មកហៀរហូរអនេកលន់ នឹងជាលីកានស្រស់មាសគន់ នឹងស្រស់សោភ័ណឧភ៉ន់ស្ងួន ៗ ណើកណាំចរិតរមច្ចាត្រី កាលផ្ទាក់ផ្ទួមបីស្រស់ទឹមទន្ទួនប្រាំរយប្រាកដយ៉ាងស៊ីប់ស៊ួន ឥឡូវសុខខ្លួនមិននឹកនា ៗ ស្ដេចតើនស្រាប់តែឃើញនាងសោក ស្ទុះក្រោកថាកើតអ្វីពីនា ឬមួយស្រីស្ងួនមិនសូវជា ចូរពៅពណ៌នាប្រាប់មកបង ៗ នាងនាថបានស្ដាប់ព្រះសន្ទុះ ទើបស្ដីទៅជាក់តាមទំនង ពីទឹកណើកណាំ ទោះជាម្ដង ស្ដេចជ្រាបឥតហ្មងហើយថ្វាថ្លែង ៗ កុំប្អូនព្រួយប្រាណកល្យាណី ព្រឹកយើងចេញខ្លីលាតម្ដង ព្រមទាំងសេនាឥតបំបែង ចាត់ចែងតាមបង្គុំសោកអ្វី ៗ នារីបានស្ដាប់សព្ទុកាទ ដែលព្រះភូមិនរបតី ទ្រង់មានឧត្តាយ៉ាងខ្វី ៗ សត្រីស្ដាប់បានមិនសោកសៅ ៗ បុព្វសមយេអរុណរះ ឡើងខ្ពស់ស្រឡះឃើញសន្ធៅ សុវណ្ណហង្សព្រមទាំងផោម

ស្រណោះ យាងសំណៅប្រាសាទបិតា ។ ខនកាយក្រាបថ្វាយវិវន្ទា
បង្គំសូមលាអង្គក្សត្រា ចេញទៅកំសាន្តនៅនាមហា សមុទ្រផលសា
ណើកណាំនៃ ។ នឹងជូនស្រីស្ងួនទៅតបគុណ សូមព្រះមានបុណ្យ
គិតលក់លៃ តបគុណណើកណាំមច្ឆាវ៉ៃ សូមទានរំពៃឲ្យកូនទៅ ។
ព្រះបាទសុធនរតន៍ចើងថ្កាន សឹងស្ដាប់ជាក់ស្រាន់ឥតហ្មងសៅ បើកឲ្យ
កូនស្ងួនមិនយូរនៅ ព្រមទាំងពាលពៅបុត្រធើតឆាយ ។ សុវណ្ណហង្ស
ទ្រង់មានរាជបញ្ជា ហៅអស់យោធាផងទាំងឡាយ គ្នាយើងរៀប
ពលឲ្យសប្បាយ នឹងជូនកាយអង្គអញជាមួង ។ សេនីមានទាំងកំពល
យក្ស ទ័ពប្រើនអនេក្សរៀបអឹងកង ក្របីដំរីសេះរថផង ថ្វាយ
ក្សត្រច្បាស់ច្បង់បានសព្វគ្រប់ ។ រួចហើយស្ដេចនាំពលមហេសី គង់
លើដំរីក្សត្រដោមមូប យាងពីបុរីព្រះបមកព ទតសព្វព្រឹក្សាផងនានា ។
លេចក៏លចូលព្រៃមីរដេរដាស ទ័ពគំខណាស់មិនយូរយា ចេញពីបុរី
គិរប់ជា ៧ ខេរ៉ាដល់ជាក់ស្ដង់ ។ ទ្រង់ឲ្យអមាត្យធ្វើរោងរម្យ ថ្វាយ
ក្សត្រឧត្ដមឥតចំបែង ក្បែរសមុទ្រជ្រៅពេលនោះឯង ថ្វាយដល់
តម្កល់ដោយមានបុទ្ធិ ។ ទ្រង់នៅសម្រាកទាំងពលផង សប្បាយអឹង
កងប្រមុំជិត សប្បាយទាំងអស់ឥតភ័យភិត ខ្វះហាប់បង្រិតស៊ីសប្បាយ ។
គង់នេះស្វេះខុកថ្ងៃណើកណាំ គ្រប់ ៧ ថ្ងៃនាងដោយឆាយ ទ្រង់យាង
ហៅពលផងទាំងឡាយ នឹងកាយខ្ពង់ជាប្អូនពិត ។ នាងជាលីការ
ស្រីជាបង ហៅពលត្រសង់មីរជិត ៧ ថ្ងៃហើយយើងរំពឹត ចេញ

ពីឋានបិតផ្ទះសិរសា ៗ ឲ្យបានសប្បាយពេលនេះឯង ចាត់ចែងរៀប
ភ្លាមស្រស់កញ្ញា ណើកណាំប្រាំរយអរអស្ចារ្យ រៀបកាយយាត្រាវិមាន
មាស ៗ ពួកស្រីប្រាំរយច្រើនពេញពោរ យានចុះទឹកឆ្លាមុជពេញ
ពាស សប្បាយគាំងអស់មិនមានទាស់ នាងចាំហែលណាស់កន្ទ
ផលស័យ ៗ មិនយូរដោយឆ្ងាប់ផាប់ចំនៀម ដល់ភ្លាមដល់ត្រើយពេល
នោះនៃ ចូលផ្ទះសិរសាឥតមានភ័យ ទើបជួបយក្សព្រៃមេនាយកង ៗ
នាងស្គាល់ដឹងថាយក្សសេនី ចូលខ្ទីតព្រួយសួរសាសង ថាហៃ
អាសុរីម្ចាស់បង ចុះស្រស់នួនល្អងនៅទីណា ៗ ក្រុងយក្សបានឃើញ
ត្រីណើកណាំ ដោយចាំការជួបទេពកញ្ញា ក៏នាំចាំងអស់ពួកមច្ឆា
ថ្វាយដល់ក្សត្រាម្ចាស់សិរសី ៗ នាងជាលីកានធុរ៉ាន់សួន បានជួប
នោមយង់ស្រស់ប្រិមប្រីយ នាំគ្នាឱបថើបត្រកងបី មេត្រីបានសួរសុខ
ទុក្ខពៅ ៗ នាងក៏សាសព្ទតាមដំណើរ មិនមានសើរើដល់ចោមផ្លៅ រាប់
រៀបសព្វគ្រប់ប្រាកដនៅ មច្ឆាទូលទៅថាសូមក្រាប ៗ សូមយាង
ព្រះនាងនឹងមហាក្សត្រ ទៅប្រាសាទរតន៍ដោយសភាព ឲ្យបានកំសាន្ត
កាយពលភាព ពិតទូលរាប់រៀបប្រាសាទមុនី ៗ នាងក៏យល់ព្រមនឹង
ក្សត្រា ទើបប្រាប់សេនាផែលនៅទី ឲ្យចាំនៅចុះព្រះភូមី ស្តេចនឹងបរ
លីទៅកំសាន្ត ៗ តែ ៧ ថ្ងៃជាកំណត់ នឹងវិលចូលវង្សដោយស្មោះ
ស្មាន សេនីក៏ចាំមិនរំខាន ក្សត្រក្សាន្តទ្រង់យាងប្រញាប់ការ ៗ
ធុរ៉ាន់នាងពក្សត្រកឧត្តម ជាលីមាសមុំពកញ្ញា ហែលផ្លូងទៅតាមនៃ

ផលសា បានដល់ប្រាង្គប្រាំពេចខ្ទិ ៗ នាំស្តេចទតសព្វទីកន្លែង ល្អ
ក្រៃគួរក្រែងឥតថេរថី ដូចស្ថានសួគ៌ាមានបារមី ចក្រីនឹងនាងសប្បាយ
ណាស់ ៗ កក្កប់ក្សួរហូរហៃក្រកបាន ក្សត្រក្សាន្តទតឃើញពិតជាក់
ច្បាស់ តាំងពីព្រលឹមភ្លឺត្រចះ ដល់ថ្ងៃមិនច្បាស់ពេលប់លន់ ៗ ជា
លីការនាំអគ្គមហាក្សត្រា នឹងស្រស់កញ្ញាមាសត្បូងតន់ ចូលជុំនៅក្រែ
មាសសុវណ្ណ ពីរអគ្គកង្កនកើតស្នួស្ដ៏សម ៗ នាងកេតសុរិយគ្គដោយនឿយ
កាយ នាងផ្ទុំលក់សាយស្រស់មាសមុំ ថ្ងៃងពីដោមធាយព្រះបរម ឃើញ
ព្រះនាងផ្ទុំលក់ជាម្ដង ៗ ទ្រង់ដកថយខ្លួនបរយាត្រា ទៅរកកញ្ញាស្រស់
ទន្លង ឱកាន់ស្រស់ស្រីឥតសៅហ្មង ចូលផ្គងទៅដល់ប្រាសាទស្រី ៗ
ឃើញនាងផ្ទុំលក់មិនដឹងកាយ ដោមធាយកៀកឱបកល្យាណី រួបរឹតកេះ
ថាហៃប្រិមប្រិយ សូមទទួលប្ដីណាមាសមិត្រ ៗ នាងភ្ញាក់ដឹងកាយ
ទតយល់ក្សត្រ ខ្លាចកើតវិបត្តិភ័យភិត សៅហ្មងទើបទូលព្រះទ្រង់ឫទ្ធិ
ថាឱបពិត្រជីវិតប្អូន ៗ ហេតុម្ដេចក៏ទ្រង់មិនអាណិត ចូលមករួបរឹត
ដល់ស្រីស្ងួន ក្រែងម្ចាស់បងដឹងយ៉ាងស៊ប់ស្ងួន កើតរឿងធំធ្ងន់ណា
ត្រាណត្រើយ ៗ ស្ដេចស្ដាប់ថាប្អូននាងកុំភ័យ បងលៃឲ្យស្រួលណា
ប្អូនអើយ មកអាយបងសូមប្រាណកៀកកើយ កែវកុំកន្ដើយណាមាស
មេ ៗ នាងស្ដាប់សាសព្ទព្រះដោមយង់ ដែលឱបក្រញូក្រុងស្រីដោម
ស្នេហ៍ មិនអាចប្រកែកតេចប្រែកែ តាមតែព្រះអគ្គរមេត្រី ៗ ស្ដេច
បានឱកាសឱបយ៉ាងស្និទ្ធ រួបរឹតនឹងអគ្គព្រះប្អូនស្រី ដើងចាស់មកបះនឹង

ដើរខ្ចី បក្រិបត្រែស្ទើរបាត់កាយ ។ រួចហើយមិនយូរទ៉ឹន់ស្ងួន ឱន ខ្លួនបង្គំក្សត្រតោមឆាយ ថាសូមព្រះអង្គជ្រាបឧបាយ ប្អូនសូមថ្វាយ ខ្លួនធ្វើជាខ្ញុំ ។ ធ្វើម្តេចបានមករួមមេត្រី បេតីជាមួយទូលបង្គំ សូម ជ្រកក្រោមល្អងព្រះបរម សូមសុំតែសុខតរៀងទៅ ។ ស្តេចស្តាប់ សាសព្រស្រស់ទឹមទ្លួន ថ្វាយខ្លួនដល់អង្គក្សត្រព្រះចៅ លោកក៏អាសូរ ដល់ពាលពៅ ឆ្លើយថាហៃឆ្មៅមាសដីវី ។ បងមិនចោលពៅប្អូនឯង ទេ កុំមេព្រួយព្រាណណានារី បងមិនចោលពៅតាមពាទី នាងជឿ ក្ដីពេលនេះម្ដង ។ រួចហើយស្ដេចលានាងចេញទៅ សំដៅដាលីកាន ត្រាវជាបង ដោយឃើញពីថ្ងៃប្រាសាទផង ចូលផ្គងឃើញស្រីនៅ និទ្រា ។ ស្ដេចឡើងទៅឧបមិនដឹងខ្លួន នាងទ្រួនភ្ញាក់ព្រឺតឃើញពជា ញាក់ព្រាណមិនហ៊ានទឹងពណ៌នា ពជាមេត្រីរួមស្នេហ៍ស្និទ្ធ ។ មិន ហ៊ានងើបមើលព្រះអង្គក្សត្រ ប្រតិបត្តិថ្វាយខ្លួនឲ្យទ្រង់បុត្រ សេពកាម ទៅតាមអំពើចិត្ត ផ្តេកផ្តិតកៀកកាយសប្បាយក្រៃ ។ រួចហើយនាង ក្រោកថ្វាយវន្ទា ដល់អង្គពជាចមកពក្រៃ ខ្លាចតែសុរិយគ្គស្រស់បរណៃ កៃខែដឹងដានប្រាណសៅហ្មង ។ ទូលថាក្រែងតែសុរិយគ្គពៅ នាងដឹង ជាក់ទៅព្រួយកន្ទង ប្អូនស្រីសូមជ្រកនៅក្រោមល្អង នៃព្រះបាទបងធ្វើ ជាខ្ញុំ ។ ស្ដេចថាកុំព្រួយណាឆេតឆាយ បងពាំបរងកាយស្រស់មាសមុំ កុំប្អូនព្រួយចិត្តគិតបារម្ភ បងផ្សំឲ្យសុខណាមាសមិត្ត ។ កៀកកើយ រួចហើយស្ដេចយាត្រា ទៅវៃបពីតាធ្វើនៃបនិត្យ នាងក៏មិនដឹងការ

ដោយពិត ស្មានថាទ្រង់បុទ្ធផ្ទុំលក់នៅ ៗ លុះព្រឹកសុរិយាខ្ពស់អស្ចារ្យ ក្សត្រាតើនក្ខាមឥតហ្មង់សៅ ក្រសាលសប្បាយនឹងពាលពៅ ឆោមឆ្ងៅសប្បាយពល់កាត្រី ៗ លុះបានចំនួន ៧ ថ្ងៃ ឆោមថ្ងៃអណ្ដុន្គ នារីស្រី ថាសូមព្រះបង់វិលបុរី ដើម្បីនឹងទៅក្រុងសេមា ៗ ស្ដេចទ្រង់ឆ្លើយតបទៅប្អូនខ្មី ថាហៃព្រលឹងសូមយាត្រា បងជូនប្អូនទៅខ្មេរផលសា ហើយលាកញ្ញាមិនទៅទេ ៗ ផ្សិតបង់បានរួមហើយស្នេហ៍ស្និទ្ធ នាងទាំងពីរពិតណាមាសមេ បងនៅមួយឆ្នាំទើបវិលរេ មាសស្នេហ៍សូមទូលបិតាផង ៗ នាងកេតសុរិយន្គបានស្ដាប់ជាក់ អួលអាក់ប៉ុន្ដែមិនសាសង ដោយគេមានគុណធំកន្ទង នាងផ្សងតាមព្រេងអនាគត ៗ ឯនាងរៀបកាយឆាយឆោមឆើត ទ្រង់ស៊ើតណើកណាំជូនប្រាកដ ចេញពីប្រាសាទនៃមាសរត្ន សន្មតហៃនាងធ្ងន់ទឹកខ្មី ៗ ជាលីកាននាងពកេតសុរិយន្គ ទ៉ក់ទពអង្គព្រះចក្រី វៃហលធ្ងន់សមុទ្រជូនស្រស់ស្រី បានដល់ច្រាំងនៃមិនយូរឡើយ ៗ នាងនាថលាត្រីនឹងកស្ដា ថាសូមក្សត្រាអង្គត្រាណត្រើយ កុំនៅយូរពេកព្រះអង្គអើយ ប្អូនសូមលាហើយណាឆោមឆាយ ៗ ណើកណាំសោកស្ដាយកាយនួទល្អង ដែលធ្លាប់សាសង់ឃើញរូបកាយ ដល់នាងយាងបាត់មិនសប្បាយពលផងទាំងឡាយដែលចាំនៅ ៗ លាត្រីនឹងអង្គម្ចាស់ជីវិត នាំស្រីវរមិត្រស្រស់ពាលពៅ ឡើងគង់ហត្ថីបរចេញទៅ សំដៅក្រុងត្រៃកបុរីរម្យ ៗ កំពលក្រុងយក្សជាទ័ពស្រេច ដើរហូបសប្បាយហើយប្រឹងខំ

សំរៅបុរីក្សត្រិឧត្តម រៀបចំតាក់តែងមិនយូរយា ។ ពេះតែខំប្រឹងមិន
ឈប់ឡើយ បានទៅដល់ហើយ ៧ ទេព ពលក៏ចូលដល់ទៅខ្លោងទ្វារ
ពួកក្រសួងនានាទទួលជាស ។ នាងស្រីឡើងទៅព្រះបិតា ទូលពីកស្ត
ក្សត្រជាម្ចាស់ ពីបានណើកណាំនោះឯងច្បាស់ ប្រាប់កិច្ចរហ័សគ្រប់
ព្រាទី ។ ទូលហើយនាងទៅឯដំណាក់ ក្រុងក៏ពលយក្ខលើកអញ្ជលី
បង្គំចំពោះស្រស់នារី និងសូមចរលើទៅស្ថានស្ថិត នាងក៏អនុញ្ញាតស្អាត
ប្រសើរ ក្រុងយក្សក៏ដើរសំដៅពិត ចំពោះសុធនរតនជីវិត បង្គំពិនិត្យ
លាក្សត្រា ។ ស្តេចក៏ឲ្យពរថាទៅចុះ ឲ្យមានកេរ្តិ៍ឈ្មោះល្បីអស្ចារ្យ
សូមទៅឲ្យសុខដូចប្រាថ្នា យក្សាចុះក្ដាមហោះចេញខ្ចី ។ ដោយ
យក្សមានឫទ្ធិហោះមិនយូរ ឫទ្ធិធូរមន្តខ្លាំងពូកែល្បី មួយភ្លែតបានដល់
ទៅបុរី រាស្ត្រយក្ខប្រុសស្រីអរពេញកាយ ។ ក៏នៅស្ថានសុខផុតទុក្ខ
ភ័យ ត្រង់នេះយើងលៃឈប់និយាយ ថ្លែងសុវណ្ណហង្សគន្ធដើតធាយ
ដែលជូនព្រះកាយកេតសុរិយង្គ ។ រួចហើយទុក់ទំជាលីការ នាំក្សត្រ
សោភ័ណមានឫទ្ធិទ្រង់ នាំចរទៅឋានយ៉ាងបព្ចគ្គ គង់ក្នុងប្រាសាទមាស
វិស័យ ។ ណើកណាំប្រាំរយថ្វាយជាខ្ញុំ មាសម៉ុំទាំងពីរដើមក្សត្រ
ថ្លៃ ស្នេហាប្រាកដសាបិត្រ្តិ យូរខែឆ្នាំថ្លៃសែនសប្បាយ ។

## បទកាកគតិ

កាលនោះក្រសត្រ ព្រួយព្រះទ័យក្តាត់ កើតក្តីខ្វល់ខ្វាយ នឹក
ដល់បិតា មាតាទាំងឡាយ ទើបទ្រង់ប្រាប់ប្រាយ ទៅណើកណាំថា ៗ

ហៃប្អូនពិសី បងនៅគ្រប់បី ឆ្នាំហើយកញ្ញា កែវទន់ស្ងួន មានគតិ ផងណា ប្អូននាងរក្សា គតិឲ្យសាន្តសុខ ៗ បងមិនបោលស្រី ប្អូន កុំព្រួយអ្វី ណាមោមទ្រលុក ប្អូនរក្សា ឲ្យបានផុតទុក្ខ តទៅខាង មុខ ទើបមានសិរី ៗ នាងផាលីកាន ព្រមទាំងទន់ ស្រស់កល្យា- ណី នាងព្រាត់កស្តា ជាសង្សារថ្មី ព្រាត់ប្រាសពីសី នាងកើតមួហ្មង ៗ យំសោកបោកកាយ ស្តាយអើយសែនស្តាយ ព្រះអគ្គជាប្យង់ មិន គួរយាងបោល ស្រីស្រស់ទន្ទង ថ្ងៃក្រោយព្រះបង សូមវិលមកណា ៗ ស្តេចថាប្អូនស្រី នាងកុំព្រួយអ្វី ពីបិត្តកស្តា ថាមិនបោលទេ មេកុំ សង្កា បេះដូងជេដ្ឋា ទៅកុំកន្ទើយ ៗ នាងនាថបានស្តាប់ ទើប នួនស្រែកប្រាប់ ថាគ្នាយើងអើយ ជូនអគ្គស្វាមី ទៅបុរីហើយ ហង កុំព្រងើយ ជូនស្តេចចលើ ៗ ឯពួកពេរីករណាំ មកមីរជួបគ្នាម ហែព្រះភូមី ហែលធ្វងគង្គា សំដៅទៅទី ចំប្រឹងចលើ បានដល់ត្រើយ ត្រាណា ៗ ហើយលានួនស្រី ទន់យាងដើរខ្ជី តែអគ្គឯកប្រាណ នាងក៏យំសោក ស្តាយអគ្គក្សត្រក្សាន្ត ដោយនាងមិនបាន ជួបអគ្គ ក្សត្រា ៗ ហើយវិលត្រឡប់ នាំពលប្រញាប់ ចូលទៅប្រាង្គណ៍ប្រា សាទសុខសប្បាយ ទាំងគ្រប់រូបា គ្មានកើតទុក្ខា ព្រួយនឹកពីអ្វី ៗ ថ្ងៃងពីព្រះអគ្គ ទ្រង់ចំត្រាប់ត្រង់ សំដៅបុរី ក្បួនអស់ឈើផង គ្មាន ដឹងពីអ្វី ដោយកែនឹងស្រី ក្បួនបុរីរម្យ ៗ យាងដើរវង្វេង ខាង ស្តាំជាឆ្ងាយ ទ្រង់ព្រួយបារម្ភ ប៉ុន្តែប្រឹងយាង ព្រះទ័យប្រឹងខំ ឆ្ពោះ

រតនឧត្តម ព្រៃយក្រៃកន្ទង់ ៗ យានដានដប់ថ្ងៃ ឃើញក្រុងបុរី មួយ
ធំបម្យង់ ស្អាតសូន្យមនុស្សម្នា គ្មានឃើញជាអ្ដង ទ្រង់គិតមួយហ្នង
កើតក្ដីសង្ស័យ ៗ យានចូលមីមា ឃើញស្អាតអស្ចារ្យ ក្នុងពេល
នោះនៃ ទ្រង់យានចុះឡើង មើលឋានទីទៃ ឥតឃើញមានអ្វី នឹក
ឆ្ងល់ពន់ពេក ៗ លុះបានទតទៅ ឃើញស្គរមាសនៅ ហៅសែនល្អ
ឯក ទ្រង់យានទៅដល់ ស្ទាប់លេងអនេក រងំហាក់ដូចដែក គោះ
ព្ធុង ៗ ៗ ស្រាប់តែមានស្រី ស្រស់កល្យាណី នាងស្រែកពីក្នុង
នរណានេះមក គោះលេងស្គរហ្នឹង ប្រយ័ត្នសូន្យឈឹង នៃជន្មជីវិ ៗ
ជ្រៀតខ្លួនខ្ញុំណា មាតាបិតា យកមកទុកទី ដើម្បីបៀសវាង ពីសត្វ
ឥន្ទ្រីយ វាដឹងមកស៊ី ឥឡូវហើយណា ៗ វាស្រូតាំងប្រុសស្រី ស៊ី
គ្មានសល់អ្វី មាតាបិតា នៅតែខ្ញុំមួយ ទ្រាំរងទុក្ខា អើលោកអ្នកណា
សូមអញ្ជើញទៅ ៗ ស្ដេចស្ដាប់មាត់ស្រី ទាញព្រះខ័នខ្លី វះស្គរ
ដែលនៅ ឃើញរូបធើតឆាយ ទើបស្ដេចសួរទៅ ហៃប្អូនពាលពៅ ម្ដេច
មករងទុក្ខ ៗ មិនអីទេស្ងួន បងមកជួបជួន មុខជាបានសុខ សត្វ
ឥន្ទ្រីយនោះ បូរពៅទ្រលុក វាកើតកល្យុគ ទឹងដៃខ្លួនបង ៗ ចុះគិត
ធ្វើម្ដេច ឲ្យបានដឹងកិច្ច ដល់សត្វជាម្ដង បូរពៅពិសី ស្រីនាងសា
សង ឲ្យដឹងកន្ទង ដំណើរនេះឯង ៗ នាងក្រាបទូលថា ឥន្ទ្រីយ
នោះណា វាចាំមើលផ្លែង ឲ្យតែឃើញពិត វាប្រឹងខ្វាត់ខ្វែង ហើរ
ឥតចំបែង វាដឹងមានមនុស្ស ៗ ស្ដេចស្ដាប់កាលណា ទ្រង់ចរយាត្រា

ទៅរើសបានទុស មកដុតភ្លាម ៗ ទើបកើតផ្សែងនោះ ហុយឡើងចំ
ពោះ លើនគាល័យ ៗ ថ្ងៃឯសត្វបក្សា ឃើញផ្សែងកាលណា ហៅ
គ្នាឆាប់រំ ថាគ្នាយើងអើយ មើលផ្សែងនោះនែ មានមនុស្សប្រែ
យើងទៅស៊ីព ៗ ឥន្ទ្រិយទាំងឡាយ ប្រឹងហើរប្រញាយ ចំដណ្តើម
គ្នា មកដល់ឃើញក្រិត ទើបពោលពណ៌នា រុំយមនុស្សកំព្រា
មកកាយអញស៊ី ៗ ឆាប់ៗកុំនៅ តិចអញស្ទុះទៅ ចិកក្បាលនៅ
ទី ស្តេចស្តាប់ប្រាកដ អគ្គតូទ្រពោធិ ស្តីនៅឥន្ទ្រិយ រុំយសត្វប្រែ ៗ
ឯងកុំមើលងាយ ក្រែងលោស្លាប់ពាយ ទាំងកណ្តាលថ្ងៃ ឆាប់ហើរ
ឲ្យឆាប់ ចូលទីព្រឹក្សព្រៃ បានអាផុតភ័យ នៃដៃអញផង ៗ ឥន្ទ្រិយ
ស្តាប់ជាក់ ថាយើមនុស្សម្នាក់ រាហ៊ានសាសង៍ អញស៊ីក្បាលអា
ឲ្យឃើញហ្មត់ហ្មង ថាហើយហើរផ្គង សំដៅពជា ៗ ស្តេចទតបក្សី
ព្រះហើនឥតបី ឥតបើគណនា ទាញព្រះខ័នមុនី បោលលើមេឃា
ព្រះខ័នក្លាយជា អាវុធច្រើនណាស់ ៗ កាត់កបក្សី ធ្លាក់មកពេញ
ព្រៃ មើលទៅដេរដាស គ្មានសល់ដល់មួយ ព្រះខ័នក្រឡះ មក
ដល់ហត្ថម្ចាស់ ដូចដើមវិញជាក់ ៗ ទើបស្តេចយាងទៅ ចូលថ្មស្រី
ពៅ អគ្គីមវរល័ក្ខណ៍ នាងមើលឥន្ទ្រិយ សូន្យជីពជន្មជាក់ ស្លាប់ច្រើន
អនេក្យ អនេកពេញដី ៗ នាងទតយល់ហើយ ស្រស់ស្រីត្រាណ
ត្រើយ ខ្លាចអគ្គចក្រី ក្រញូវក្រាបវន្ទា សូមធ្វើស្វាមី ថ្វាយខ្លួនស្រស់
ស្រី សូមធ្វើជាខ្ញុំ ៗ ស្តេចកៀកព្រលឹង នៅក្នុងទីហ្នឹង ស្រស់ស្រីមាសមុំ

នាងចំស្ដេចចាស់ ប៉ះភ្លាមក្រញ្ញក្រៀ ក្រេបស្នាតស្ងួន តាំងទ្រកាយា ៗ
អស្ចារ្យចំឡែក ក្រុងនាគមុជជ្រែក នៅក្នុងជលសា ព្រះសុវណ្ណហង្ស
នឹងអង្គកញ្ញា សំរើបតណ្ហា ប្រកៀកនិត្យនៅ ៗ រួចស្រេចជាម្ដង
សម្ដេចបក្សាសច្បង ទ្រង់ស្ទួរស្រីពៅ ហៅកែវជីវិត នាងឈ្មោះអីទៅ
ចូលស្រីប្អូនខ្ពៅ ប្រាប់មករៀមច្បង ៗ នាងទូលតបថា ខ្ញុំនេះឯង
ណា ឈ្មោះអកឹមល្អង សូមថ្វាបព្រះទ័យ ក្នុងពេលនេះហោង សូម
ផ្ដែកក្រោមល្អង អង្គព្រះស្វាមី ៗ ស្ដេចថ្វាបថាក់បក្សា នៅក្បត្រ
ម្ចាស់. ស្រស់កល្យាណី ស្ដេចកំស្នេហ៍ស្និទ្ធ នឹងស្រស់ប្អូនស្រី រួច
ហើយចក្រី ត្រាស់ស្ទួរប្អូនស្ងួន ៗ ហៅតាមព្រលឹង នៅក្នុងពេល
ហ្នឹង បងបង់វិលខ្លួន ទៅកជបុរី នឹងយកនិមន្ទន តើស្រស់មាសស្ងួន
នាងជាផ្ដូចម្ដេច ៗ នាងថានាងខ្ញុំ សូមថ្វាយបង្គំ ប្រគល់សម្ដេច
បង់យកទៅណា នោះថ្វាយខ្លួនស្រេច ដើរតាមអង្គស្ដេច ឥតមាន
ប្រែកែក ៗ ស្ដេចស្ដាប់ជាក់ហើយ ដឹងប្អូនត្រាណត្រើយ ស្រីផាតាម
ឯក សុខចិត្តតាមអង្គ មិនមានបង់បែក នាងមកពឹងផ្អែក លើម្ចាស់
ជីវិត ៗ ថាបើដូច្នោះនៃ ទើបអង្គក្សត្រិថ្ងៃ នាំនាងវរមិត្រ យាងពី
សេមា នឹងព្រះទ្រង់ឫទ្ធិ នាំស្រស់ឆោមស្និទ្ធ ឥតមានមួហង ៗ
យាងកាត់ផ្លុងព្រោយ សំដៅបណ្ដាយ នឹងកែវទូនល្អង ទៅក្នុងព្រឹក្សា
នឹងអង្គបក្សាសច្បង ត្រាច់តាមដោយផង ក្បែរផ្លូវបត្តា ៗ ស្ដេចទត
សព្វព្រៃ ព្រឹក្សផងទីទៃ ខំបរយាត្រា នឹងអកឹមទូន តាមដោយ

ព្រឹក្សា លំបាក់អាត្មា ពន់ពេកឥតស្បើយ ៗ ប៉ុន្តែចំប្រើង ទាំងនោម
ព្រលឹង ស្រីស្រស់ត្រាណត្រើយ ៧ទេព បានដល់ជាក់ហើយ ឥត
មួយហ្ន៎ឡើយ ស្តេចស្តាប់ជាក់ច្បាស់ ៗ ចូលក្នុងបុរី ព្រមទាំងពីសី
នោមឆាយល្អល្អះ ពួកកាស្រ្តីប្រជា មកមីរដេរដាស ទទួលក្សត្រម្ចាស់
គ្រប់គ្រងផែនដី ៗ ហៃហាមព្រះអង្គ ទាំងស្រស់នោមយង់ ឡើង
ប្រាសាទទ្វី បង្គំទ្រង់ឫទ្ធិ ត្រូវជាវរបី ទាំងមាតាថៃ ហើយក្រាបទូល
ថា ៗ បពិត្រព្រះគុណ ទ្រង់មានគុណធ្ងន់ ខ្ញុំនកូនខេះណា ដែល
រួមណើកណាំ អស់បីវស្សា ហើយចរយាត្រា ដើរចូលក្នុងព្រៃ ៗ
ចំប្រើងមុំមា ដើរដោយមាគ៌ា មកជាច្រើនថ្ងៃ ស្រាប់តែបានជួប ទាំង
អគ្គីមស្រី ស្តេចទូលសេចក្តី មិនឲ្យសល់ខាន ៗ តាំងពីដើមឃ្លា
ជួបបានពណ៌នា ជាគោលល័ក្ខដ្ឋាន សុធន់នោមឆាយ ស្តេចក៏ស្តាប់បាន
អាណិតកល្យាណ បុត្រប្រសាណាស់ ៗ

(ភាគទី ៣ ចប់ហើយ)

នៅមានភាគទី ៤ តទៅទៀត

១៨- អន្តរធានកថា ថ្លៃ ១០៛០០

១៩- រឿងផាក ថ្លៃ ១០៛០០

២០- រឿងព្រះបាទជយវរ្ម័ន ទី៧ ពាក្យកាព្យយ៉ាងពីរោះ ថ្លៃ ៥៛១០

២១- ប្រស្នាកច្ចាយនូបត្ថម្ភកៈ នាមនិទ្ទេស ទី ២ ថ្លៃ ២០៛០០

២២- ច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ថ្លៃ ១០៛០០

២៣- ជីវណកថា ថ្លៃ ៣៛០០

២៤- អនុពុទ្ធប្រវត្តិ ថ្លៃ ៧៥៛០០

២៥- បណាមគាថា ថ្លៃ ៣៛០០

២៦- អវិជ្ជាកថា ថ្លៃ ២២៛០០

២៧- សុភាសិតសង្គ្រោះ ថ្លៃ ១៦៛០០

២៨- រឿងបុទ្ធិវង្ស ទី ១ ២ ថ្លៃ ៨៛០០

២៩- បីភាសា ខ្មែរ-ចិន-យួន ថ្លៃ ១០៛០០

៣០- រឿងវរនេត្រវរនុជ ទី ១ ថ្លៃ ១០៛០០

៣១- រឿងសុវណ្ណហង្ស ទី ១-២ ថ្លៃ ១០៛០០

៣២- ព្រះមហោសថ ទី ១ ថ្លៃ ១០៛០០

៣៣- សំយោគវិធាន ថ្លៃ ១៣៛០០

៣៤- អរិយមគ្គាធិប្បាយ ថ្លៃ ២៦៛០០

៣៥- វេយ្យាករណបទីប ថ្លៃ ៤០៛០០

៣៦- វត្តក្ខន្ធកៈ ទី ១៨ ថ្លៃ ៦៛០០

៣៧- ទុល្លភធម៌ ថ្លៃ ៧៛០០

ព្រមទាំងមានលក់សៀវភៅបារាំង ប្រដាប់សម្រាប់គ្រូ-សិស្ស

សំបុត្រលិខិតផ្សេងៗ ជាច្រើន ។